## ព្រះរាជាណាចក្រកម្ពុជា

*ជាតិ សាសនា ព្រះមហាក្សត្រ*

## រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ឆ្នាំ ២០១៤

គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ

# អារម្ភកថា

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងការគោរពដ៏ខ្ពស់ខ្ពស់ និងកតវេទិតាដ៏ស្មោះត្រង់ចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រយ៉ាងពេញទំហឹង និងយកចិត្តទុកដាក់ខ្ពស់បញ្ហាបរិស្ថានពិសេសការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិប្រកបដោយសមស្រប ដើម្បីជួយលើកកំពស់សេដ្ឋកិច្ចជាតិ ព្រមទាំងជួយកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងតំបន់ដែលងាយទទួលរងគ្រោះខ្លាំងបំផុត។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះនឹងជាមាគ៌ាដល់ដំណើរការ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ព្រមទាំងជាមធ្យោបាយ សម្រាប់ការអនុត្តតំបន់ទាំងនេះ។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនេះ ក៏គឺជាត្រីវិស័យបង្ហាញផ្លូវមួយសម្រាប់ រៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិគ្រប់ប្រភេទនៅកម្ពុជា ដូចមានចែងនៅក្នុងជំពូក៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ដែលត្រូវរៀបចំឡើងដោយក្រសួងបរិស្ថានសម្រាប់ឲ្យមានការអនុម័ត្តពីរាជរដ្ឋាភិបាលកម្ពុជា។ ហើយផែនការបគ្រប់គ្រងជាយុទ្ធសាស្ត្រនេះ នឹងជួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិសម្រាប់ការរៀបចំផែនការសកម្មភាពនៅតំបន់ការពារធម្មជាតិនីមួយៗ។ ក្នុងន័យនេះ ខ្ញុំមានមោទនភាពចំពោះក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះណាស់ ដែលឆ្លើយតបទៅនឹងភាពចាំបាច់របស់ប្រទេសកម្ពុជា សម្រាប់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលបានរៀបចំឡើងក្រោមការដឹកនាំសម្របសម្រួលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះ គឺជាឯកសារយុទ្ធសាស្ត្រពេញលេញលើកដំបូងបង្អស់ ដែលសម្រេចបានក្រោមការដឹកនាំដ៏ឈ្លៀសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មកពីក្រសួង ស្ថាប័នជំនាញ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការរៀបចំឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ ឱ្យសម្រេចជារូបរាងឡើង។

ដំណើរការសំខាន់ៗសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះរួមមាន សិក្ខាសិលាថ្នាក់ជាតិចំនួនពីរដង កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញចំនួនពីរលើក និងការចុះទៅពិនិត្យមើលស្ថានភាពតំបន់ការពារធម្មជាតិជាក់ស្តែង និងព្រមទាំងការពិគ្រោះយោបល់ជាមួយមន្ត្រីថ្នាក់ខេត្ត អង្គការពាក់ព័ន្ធនានា និងប្រជាសហគមន៍ មូលដ្ឋានជាច្រើនលើកទៀតផង។ សិក្ខាសាលាលើកទី១បានរៀបចំឡើងមានរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី ២៧ ដល់ ២៨ ខែសីហា ឆ្នាំ២០១៣ ដែលមានអ្នកចូលរួមមកពីស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ និងអ្នកពាក់ព័ន្ធ ផ្សេងៗទៀត។ អរគុណដល់អ្នកពាក់ព័ន្ធទាំងអស់ដែលបានធ្វើឱ្យសិក្ខាសិលានេះបានទទួលនូវ សមិទ្ធិផលប្រកបដោយផ្លែផ្កាក្រោមការពិគ្រោះ

យោបល់ពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់ឲ្យបាននូវចំនុចគន្លឹះសម្រាប់ បញ្ចូលទៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា ពិសេសការពិភាក្សាទៅលើចក្ខុវិស័យ បេសកម្ម និងគោលបំណងជាយុទ្ធសាស្ត្រទាំងបី ព្រមទាំងការកំណត់នូវសកម្មភាពសំខាន់ៗរបស់យុទ្ធសាស្ត្រនីមួយៗ ដូចដែលមាននៅក្នុងសេចក្ដីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះ។ ព័ត៌មានគ្រឹះ និងចម្បងស្ដីពីស្ថានភាពប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះ គឺទទួលបានពីស្ថាប័នគោលពីរ៖ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈបទបង្ហាញជាច្រើន នៅក្នុងសិក្ខាសិលាជាតិលើកទី១។ សិក្ខាសិលាជាតិលើកទី២ បានរៀបចំឡើងរយៈពេលមួយថ្ងៃនៅថ្ងៃទី ២៧ កញ្ញា ឆ្នាំ២០១៣ ដែលសិក្ខាកាមភាគច្រើនបានបន្តពីសិក្ខាសាលាជាតិលើកទីមួយ។ សិក្ខាសិលាជាតិលើកទី២ នេះបានពិភាក្សាយ៉ាងល្អិតល្អន់ និងស៊ីជំរៅ លើសេចក្ដីព្រាងចុងក្រោយរបស់ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ នៅកម្ពុជាមុននឹងដាក់ជូនអង្គប្រជុំគណៈកម្មការជាតិគ្រប់គ្រងជីវៈចម្រុះ ពិនិត្យ និងអនុម័ត នាពេលនេះ។ រហូតដល់ថ្ងៃទី១៨ ខែកុម្ភៈ ២០១៤ ទើបគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះបានប្រជុំអនុម័តលើសេក្ដីព្រៀងចុងក្រោយនេះ។

ដូច្នេះក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ នឹងដើរតួនាទីយ៉ាងសំខាន់សម្រាប់ ជួយសម្រួលដល់ការដាក់បញ្ចូលតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ក្នុងរបៀបវារៈទូលំទូលាយនៅថ្នាក់តំបន់ និងថ្នាក់ជាតិ អំពីការគ្រប់គ្រងធនធានធម្មជាតិឱ្យបានសមស្រប ព្រមទាំងធានាឱ្យមានភាពចុះសម្រុងគ្នាខាងផែនការ និងគោលនយោបាយក្នុងចំណោមក្រសួង វិស័យ និងស្ថាប័នពាក់ព័ន្ធ។ ជាលទ្ធផលក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ និងជួយបង្កើនថាមពលរួបរួមក្នុងការសម្របសម្រួលថ្នាក់ជាតិ កិច្ចសហប្រតិបត្តិការ និងគ្រប់គ្រងថ្នាក់តំបន់ដែលផែនការនេះអាចនាំឆ្ពោះទៅកាន់ការអនុវត្តការរៀបចំថវិកា និងការរៀបចំរបាយការណ៍ជាលក្ខណៈប្រព័ន្ធឲ្យកាន់តែទូលំទូលាយ និងជៀសវាងការប្រើប្រាស់វិធីសាស្ត្រដោយឡែកៗពីគ្នាក្នុងការការពារ និងការប្រើប្រាស់ធនធានជាតិឱ្យសមស្រប ដើម្បីធានាសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងពេលបច្ចុប្បន្ន និងនៅពេលអនាគត។ ក្រៅពីការរៀបចំ និងអនុវត្តផែនការតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ក្របខ័ណ្ឌយុទ្ធសាស្ត្រក៏ជួយធានាឲ្យមានការការពារប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃនូវធនធានធម្មជាតិរបស់ប្រទេស និងផ្ដល់សេវានៃប្រព័ន្ធអេកូឡូស៊ី។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ស្ថាប័នជំនាញការទាំងអស់ ដែលបានផ្ដល់ និងគាំទ្រទាំងធនធានបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុង

ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលជាចំនុចចាប់ផ្ដើមដំបូងបំផុតសម្រាប់រៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាក្រសួងស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងផុសផុលក្នុងដំណើរការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនេះឡើង។

ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានរៀបរៀងឡើងក្រោមការសម្របសម្រួលពីក្រសួងបរិស្ថាន ដោយមានការចូលរួមយ៉ាងសកម្ម ពីក្រុមបច្ចេកទេសអន្តរក្រសួង ព្រមទាំងមតិណែនាំដ៏មានតម្លៃពីគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះទៀតផង។ ការចូលរួមយ៉ាងទូលំទូលាយរបស់អ្នកពាក់ព័ន្ធនានា បានធ្វើឱ្យក្របខ័ណ្ឌជាតិនេះកាន់តែមានសង្គតិភាព និងមានការគាំទ្រយ៉ាងទូលំទូលាយពីវិស័យទាំងអស់។

ការរៀបរៀងនូវក្របខ័ណ្ឌជាតិ សម្រាប់គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនេះ បានធ្វើឡើងដោយមានការជួយឧបត្ថម្ភដោយភ្នាក់ងារសហរដ្ឋអាមេរិក USAID តាមរយៈគម្រោង HARVEST និងគម្រោងគាំទ្រព្រៃឈើ និងជីវៈចម្រុះ (SFB) របស់ FINTRAC និង Windrock International។

# មាតិកា


អារម្ភកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ v

ពាក្យបំព្រួញ និងអក្សរកាត់ ........ ix

សេចក្តីសង្ខេប ........ xi

១. សាវតា ........ 1

១.១ ស្ថានភាពប្រព័ន្ធតំបន់ការពារធម្មជាតនៅក្នុងប្រទេសកម្ពុជា ........ 1

១.២ គោលបំណង នៃក្របខ័ណ្ឌយុទ្ធសាស្ត្រជាតសម្រាប់ការគ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាត ........ 4

២. ចក្ខុវិស័យ ........ 6

៣. បេសកកម្ម ........ 6

៤. គោលបំណងយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ........ 7

៤.១ គោលបំណងយុទ្ធសាស្ត្រទី១ ៖ មូលដ្ឋានចំណេះដឹងសម្រាប់ធ្វើការសម្រេចចិត្ត ........ 7

៤.២ គោលបំណងយុទ្ធសាស្ត្រទី២ ៖ ផែនការសកម្មភាព ........ 8

៤.៣ គោលបំណងយុទ្ធសាស្ត្រទី៣ ៖ សមត្ថភាពផ្នែកបរិស្ថាន ........ 10

៥. មធ្យោបាយសម្រាប់គាំទ្រការអនុវត្ត ........ 11

ឧបសម្ព័ន្ធ៖ ........ 15

ឧបសម្ព័ន្ធ ១៖ ........ 15

ឧបសម្ព័ន្ធ ២៖ ........ 17

ឧបសម្ព័ន្ធ៣ ៖ ........ 19

ឧបសម្ព័ន្ធ ៤៖ ........ 31

ឧបសម្ព័ន្ធ៥៖ ........ 39

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| **CBD** | Convention on Biological Diversity | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| **CITES** | Convention on International Trade in Endangered Species of Wild Flora and Fauna | អនុសញ្ញាស្តីពីអន្តរជាតិស្តីពីប្រភេទ ដែលជិតផុតពូជ |
| **COP** | Conference of the Parties | សន្និសិទ្ធ របស់ប្រទេសភាគី |
| **GBO** | Global Biodiversity Outlook | ជីវៈចម្រុះសកលលោក |
| **IUCN** | International Union for Conservation of Nature | សម្ព័ន្ធអន្តរជាតិ សម្រាប់អភិរក្សធម្មជាតិ |
| **MAB** | Man and Biosphere | មនុស្ស និងជីវៈចម្រុះ |
| **NBSAP** | National Biodiversity Strategy and Action Plan | យុទ្ធសាស្ត្រជីវៈចម្រុះជាតិ និងផែនការ សកម្មភាព |
| **NGO** | Non-governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| **NSDP** | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ បច្ចុប្បន្នកម្ម |
| **RAPPAM** | Rapid Assessment and Prioritization of Protected Areas Management | ការវាយតម្លៃដោយរហ័សស្តីពីអទ្ធិភាព នៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| **REDD** | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការ បំផ្លាញ និងរេចរិលព្រៃឈើ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **UNFCCC** | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ |
| **WHC** | World Heritage Convention | អនុសញ្ញាស្តីពីមរតកពិភពលោក |
| **WWF** | World Wide Fund for Nature | មូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ |

# សេចក្តីសង្ខេប

ប្រទេសកម្ពុជាគ្របដណ្តប់ទៅដោយប្រព័ន្ធការពារធម្មជាតិប្រមាណជា ២៦ភាគរយ នៃផ្ទៃប្រទេស ដែលមាន២៣តំបន់ការពារធម្មជាតិស្ថិតនៅក្រោមការគ្រប់គ្រងដោយ អគ្គនាកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងមានព្រៃការពារចំនួន ៦កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងដែនជម្រកត្រីចំនួន ៨តំបន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បច្ចុប្បន្នប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជាកំពុងទទួលរងសំពាធយ៉ាងខ្លាំង។ ដូច្នេះការបង្កើតតំបន់ការពារធម្មជាតិថ្មីៗក៏ត្រូវប្រឈមនឹងឧបសគ្គយ៉ាងច្រើន បើទោះបីជាប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះបានអនុម័តច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ព្រមទាំងគោលដៅ និងផែនការសំខាន់ៗជាច្រើនទៀតមានជាអាទិ៍ ផែនការជាតិសម្រាប់អភិវឌ្ឍន៍ប្រកបដោយចិរភាពដែលកំណត់ពីគោលនយោបាយ និងក្របខ័ណ្ឌ ដើម្បីការពារធនធានធម្មជាតិ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា។ តំបន់ការពារធម្មជាតិ និងតំបន់ អភិរក្សភាគច្រើន (ចំនួន ៨៤%) ពុំទាន់គ្រប់គ្រងមានប្រសិទ្ធិភាពនូវឡើយទេ ដោយសារតែកង្វះផែនការគ្រប់គ្រង សមត្ថភាពស្ថាប័ននៅមានកម្រិត កង្វះចំណេះដឹងបច្ចេកទេស និងកង្វះថវិកា។

នៅក្នុងបរិបទប្រទេសកម្ពុជា ប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានប្រសិទ្ធភាពមិនត្រឹមតែការពារធនធានសំខាន់ៗព្រមទាំងជាតំបន់ដែលមានតម្លៃផ្នែកអេកូឡូស៊ី និងជីវៈចម្រុះ ដូចជាប្រព័ន្ធព្រៃឈើ ភ្នំ ឆ្នេរសមុទ្រ និងទឹកសាប តែថែមទាំងផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលពឹងអាស្រ័យយ៉ាងខ្លាំងទៅលើធនធានធម្មជាតិនៅតំបន់ការពារធម្មជាតិ។ ត្រូវចងចាំថាជីវៈចម្រុះនៅក្នុងប្រភេទអេកូឡូស៊ី តំបន់ការពារធម្មជាតិ តំបន់អភិរក្សនានា បណ្តាញតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងរួមគ្នា ដើម្បីចៀសវាងការគ្រប់គ្រងដោយឡែកពីគ្នា។ ដើម្បីគ្រប់គ្រងតំបន់ទាំងនេះឲ្យប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់ ផែនការគ្រប់គ្រងយុទ្ធសាស្ត្រ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សត្រូវតែមាន ដែលមានចែងនៅក្នុងមាត្រា១៥ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ២០០៨ ហើយផែនការនេះអាចជាគោលការណ៍ណែនាំដ៏ល្អបំផុតនិងអាចធានាឲ្យមានការប្រើប្រាស់ឲ្យមានប្រសិទ្ធផលបំផុត នៃស្ថានប័នជាតិ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិបានកំណត់ថាក្របខ័ណ្ឌដូចជា គោលការណែនាំ រចនាសម្ព័ន្ធ និងផែនការអាទិភាព

របស់រដ្ឋាភិបាលផ្សេងៗទៀតដែលជាជំហានដំបូង ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ នូវផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រ។

យោងតាមតម្រូវការ និងភាពចាំបាច់នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ទើបអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន បានសហការជាមួយអង្គការដៃគូ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនេះឡើង ក្រោមការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដោយភ្នាក់ងារសហរដ្ឋអាមេរិច USAID តាមរយៈគម្រោង HARVEST និង SFB អនុវត្តដោយ FINTRAC និង Windrock International ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន។

ដំណើរការសំខាន់ៗសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះ រួមមានសិក្ខាសាលាថ្នាក់ជាតិចំនួនពីរដងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញចំនួនពីរលើក និងការចុះទៅពិនិត្យមើលស្ថានភាពតំបន់ការពារធម្មជាតិជាក់ស្តែង និងព្រមទាំងពិគ្រោះយោបល់ជាមួយ មន្ត្រីថ្នាក់ខេត្ត អង្គការពាក់ព័ន្ធនានា និងប្រជាសហគមន៍មូលដ្ឋាន។ សិក្ខាសាលាលើកទី១បានរៀបចំឡើង រយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី២៧ ដល់ ២៨ សីហា ឆ្នាំ២០១៣ ដែលមានអ្នកចូលរួមមកពី ស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ សិក្ខាសិលានេះបានទទួលសមិទ្ធិផលប្រកបដោយផ្លែផ្កាក្រោមការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់ឲ្យបាននូវចំនុចគន្លឹះសម្រាប់បញ្ចូលនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា ពិសេសពិភាក្សាទៅលើ ចក្ខុវិស័យបេសកម្ម គោលបំណងយុទ្ធសាស្ត្រ និងកំណត់សកម្មភាពសំខាន់ៗនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ រហូតដល់ការរៀបចំឡើង នូវពង្រៀងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះឡើង។ នៅក្នុងសិក្ខាសាលានេះទៀតសោតក៏បានអញ្ជើញវាលគ្មិនមកពីរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមកពីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ដើម្បីបង្ហាញពីស្ថានភាពព្រៃការពារក៏ដូចជាតំបន់ការពារធម្មជាតិ នៅកម្ពុជាមុននឹងឈានដល់កិច្ចពិភាក្សា ពីចំនុចគន្លឹះសម្រាប់បញ្ចូល ទៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ។ សិក្ខាសិលាលើកទី២បានរៀបចំឡើងរយៈពេលមួយថ្ងៃនៅថ្ងៃទី ២៧ កញ្ញា ឆ្នាំ២០១៣ ដែលភាគច្រើន សិក្ខាកាមមកពីសិក្ខាសាលាលើកទីមួយ។ សិក្ខាសិលានេះក៏ទទួលបានសមិទ្ធិផលប្រកបដោយផ្លែផ្កាផងដែរតាមរយៈក្រោមការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធទាំងអស់ដើម្បីពិនិត្យឡើងវិញ និងពង្រៀងចុងក្រោយនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា សម្រាប់ដាក់ជូនអង្គប្រជុំគណៈកម្មការពិនិត្យ និងអនុម័ត។ មុននឹងពិនិត្យឡើងវិញ និងសេចក្តី

ព្រាងចុងក្រោយនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិនេះក៏បានអញ្ជើញវាលគ្មិនមកពីរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមកពីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ដើម្បីបង្ហាញផែនការគ្រប់គ្រងព្រៃការពារ និងឧទ្យានជាតិដែលបានអនុម័តផែនការគ្រងគ្រងទាំងនេះរួចមកហើយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះសិក្ខាកាមបានយល់នូវបញ្ហាប្រឈម ដំណោះស្រាយ និងយុទ្ធសាស្ត្រផ្សេងៗ ក្នុងការគ្រង់គ្រងតំបន់ការពារធម្មជាតិមុននឹងចាប់ផ្តើមរៀបចំសេចក្តីព្រាងនេះឡើង។

ក្រៅពីការរៀបចំ និងអនុវត្តផែនការតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ក្របខ័ណ្ឌយុទ្ធសាស្ត្រក៏គ្រប ដណ្តប់លើទិដ្ឋភាពតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ ដែលរួមចំណែកដល់ការរៀបចំបង្កើតតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាក្នុងប្រទេសកម្ពុជា។ ហើយប្រព័ន្ធតំបន់ការពារធម្មជាតិនេះដោយមានសំពាធ យ៉ាងខ្លាំងទាំងពេលបច្ចុប្បន្ន និងអនាគតពិសេសការប្រែប្រួលអាកាសធាតុ និងជានាំឲ្យមានការការពារប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃនូវធនធានធម្មជាតិរបស់ប្រទេស និងផ្តល់សេវានៃប្រព័ន្ធអេកូឡូស៊ី។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះមានចក្ខុវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

**ចក្ខុវិស័យ៖** ប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជារួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ ប្រកបដោយចិរភាពក្នុងនោះរួមទាំងការកាត់បន្ថយភាពក្រីក្រ ពិសេសតាមរយៈការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព នូវធនធានជីវៈចម្រុះ ធម្មជាតិ វប្បធម៌ និងប្រព័ន្ធអេកូឡូស៊ី។

**បេសកកម្ម៖** ផ្តល់នូវការណែនាំសំខាន់ដល់ ៖

- (ក) ផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិដែលបានរៀបចំ និងអនុវត្ត ដើម្បីជានាឈានទៅសម្រេចបាន នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពប្រសិទ្ធផល និងស្មើរភាពគ្នាបំផុតនៃតំបន់ទាំងអស់នៅកម្ពុជា
- (ខ) បើអាចធ្វើបានត្រូវពង្រីកប្រព័ន្ធតំបន់ការពារធម្មជាតិ ព្រមទាំងការបង្កើតតំបន់ច្រករបៀងអេកូឡូស៊ី នៅកន្លែងចាំបាច់ដើម្បីបំពេញលក្ខខណ្ឌអេកូឡូស៊ី នៃបណ្តាញប្រព័ន្ធតំបន់ការពារធម្មជាតិព្រមទាំងការតភ្ជាប់ជាមួយតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា និងរួមបញ្ចូលយ៉ាងទូលំទូលាយនៃដែនគោក និងដែនសមុទ្រពិសេស បញ្ហាប្រឈមមុខនៃការប្រែប្រួលអាកាសធាតុ
- (គ) បង្កើនជាអតិបរមានៃផលប្រយោជន៍បរិស្ថាន និងសេដ្ឋកិច្ចសង្គមតាមគ្រប់រូបភាពពីជីវៈចម្រុះនៅតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា

## គោលបំណងយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ

សកម្មភាពទាំងអស់ ដែលត្រូវអនុវត្តដើម្បីធានាថា តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងនេះ ឆ្លើយតបទៅនឹងគោលបំណង នៃការបង្កើតតំបន់ទាំងនេះ ចាំបាច់ត្រូវវាយតម្លៃជាប្រចាំពីស្ថានភាព និង និន្នាការ មុខងារ តួនាទី និងតំលៃ ការគំរាមកំហែងនិងសម្ពាធ និងផលប៉ះពាល់ពីវិធានការ ដើម្បីដោះស្រាយ ការគំរាមកំហែង និង សំពាធ ហើយព័ត៌មានដែលបានមកពីការវាយតំលៃនេះនឹងជាផែនទីបង្ហាញផ្លូវសម្រាប់ ជ្រើសរើសសកម្មភាព និងពេលវេលាសមស្របបំផុតសម្រាប់បញ្ចូលទៅក្នុងផែនការសកម្មភាព ព្រមទាំងកំណត់ពីតំរូវការចាំបាច់សម្រាប់បង្កើនសមត្ថភាពធនធានមនុស្ស ស្ថាប័ន បច្ចេកវិទ្យា និងហិរញ្ញវត្ថុ ដើម្បីអនុវត្តន៍សកម្មភាពទាំងនេះឲ្យមាន ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ដូច្នេះក្របខ័ណ្ឌយុទ្ធសាស្ត្រ នេះមានគោលបំណងយុទ្ធសាស្ត្រ ដែលទាក់ទងទៅនឹងមូលដ្ឋានចំណេះដឹង សម្រាប់ធ្វើការសម្រេច ផែនការសកម្មភាព និងចំណេះដឹងផ្នែកបរិស្ថាន។

**គោលបំណងយុទ្ធសាស្ត្រទី១ ៖ មូលដ្ឋានចំណេះដឹងសម្រាប់ធ្វើការសម្រេចចិត្តៈ** ពង្រឹងចំណេះដឹងអំពីបណ្តាញជាតិ នៃប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់ធ្វើការសម្រេចតាមរយៈការវាយតម្លៃ ការបង្កើនចំណេះដឹង ការរៀបចំព័ត៌មានផ្សព្វផ្សាយ និងការបង្កើនចំណេះដឹងអំពីតួនាទី តំលៃ និងលក្ខខណ្ឌចាំបាច់នានា នៃតំបន់ការពារធម្មជាតិតំបន់អភិរក្សនានា និងបណ្តាញរបស់តំបន់ទាំងនេះនៅកម្ពុជា។ **សកម្មភាពអទិ្ទភាពសម្រាប់គោលបំណងទី១ រួមមានដូចខាងក្រោមៈ**

- ១.១ ការវាយតម្លៃទិដ្ឋភាពសំខាន់ៗ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា
- ១.២ បង្កើនការយល់ដឹង បង្កើតរៀបចំព័ត៌មានដោយមានមូលដ្ឋានទិន្នន័យមានលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់
- ១.៣ បង្កលក្ខណៈឲ្យអាចប្រើប្រាស់អាចរកបានយ៉ាងទូលំទូលាយ នូវព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសម្រេចចិត្ត និងបង្កើនការយល់ដឹង។

**គោលបំណងយុទ្ធសាស្ត្រទី២ ៖ ផែនការសកម្មភាពៈ** បង្កើនការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាស្របតាមទិសដៅជីវៈចម្រុះ Aichi ទី១១ និងទិសដៅ ពាក់ព័ន្ធនានា នៃទិសដៅជីវៈចម្រុះជាតិ ២០១១-២០២០ និង យុទ្ធសាស្ត្រជីវៈចម្រុះ និងផែនការសកម្មភាពជាតិ ឆ្នាំ២០០២ ដែលបាននឹងកំពុងកែសម្រួលដើម្បីអនុវត្តទិសដៅ ជីវៈចម្រុះជាតិ ឆ្នាំ២០១១-២០២០។ ដូច្នេះកម្ពុជាត្រូវខិតខំប្រឹងប្រែងដើម្បីឈានទៅសម្រេចទិសដៅទាំងនេះ ដែលនៅពេលបច្ចុប្បន្នមានភាពយឺតយ៉ាវ ក្នុងការអនុវត្តកម្មវិធីការងារ ស្តីពីតំបន់ការពារធម្មជាតិដែលបាន អនុម័តក្រោមអនុសញ្ញាជីវៈចម្រុះ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍ សហស្សវត្សកម្ពុជា និងអនុសញ្ញាផ្សេងៗទៀត

ដែលកម្ពុជាបានផ្តល់ សច្ចាប័នក្នុងនោះរួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ អនុសញ្ញាមរតកពិភពលោក និងអនុសញ្ញារាំសា (Ramsar) ស្តីពីតំបន់ដីសើម។ **សកម្មភាពអទិ្ទភាពសម្រាប់គោលបំណងទី២ រួមមានដូចខាងក្រោម៖**

២.១ ជាកិច្ចការចាំបាច់ត្រូវថែរក្សា និងស្តារឡើងវិញនូវប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានស្រាប់

២.២ ការកំណត់ និងបង្កើតតំបន់តំបន់ការពារធម្មជាតិថ្មីនិងប្រភេទតំបន់អភិរក្សនានា

២.៣ បង្កើនការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

២.៤ ជានាឲ្យមានសមធម៌ក្នុងដំណើរការធ្វើការសម្រេចចិត្ត និងការចែករំលែកផលប្រយោជន៍ដោយផ្តោតជាពិសេសចំពោះប្រជាជនដែលងាយរងគ្រោះបំផុត

២.៥ ជានាការភ្ជាប់គ្នាជាមួយ និងការបញ្ចូលគ្នានៃតំបន់ទៅក្នុងតំបន់ដីគោក និងទឹក

២.៦ ដាក់បញ្ចូលតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាទៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយតាមវិស័យនានា

២.៧ អនុវត្តលិខិតបទដ្ឋាន និងច្បាប់នានា ពិសេសកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ។ បើទោះបីជាតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ត្រូវយកចិត្តទុកដាក់បង្កើតឡើងបន្ទាប់ពីការវិភាគពីចំណុចខ្វះខាត បង្ហាញយ៉ាងច្បាស់ពីតម្រូវការ នៃការបង្កើតនោះក៏ដោយក៏ការពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងគួរតែជាសកម្មភាពមួយក្នុងចំណោម សកម្មភាពអទិភាពទាំងអស់។

**គោលបំណងយុទ្ធសាស្ត្រទី៣ ៖ សមត្ថភាពផ្នែកបរិស្ថាន៖** ពង្រឹងសមត្ថភាពផ្នែកបរិស្ថានតាមរយៈការពង្រីកឲ្យទូលំទូលាយនៃអភិបាលកិច្ចល្អ ការបង្កើនការចូលរួម ការលើកកម្ពស់កិច្ចសម្របសម្រួល និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងតំបន់ និងពង្រឹងសមត្ថភាពធនធានមនុស្ស ស្ថាប័ន បច្ចេកវិទ្យា និងហិរញ្ញវត្ថុប្រកបដោយចិរភាព។ **សកម្មភាពអទិ្ទភាពសម្រាប់គោលបំណងទី៣ រួមមានដូចខាងក្រោម៖**

៣.១ បង្កើនការចូលរួម និងពង្រឹងអភិបាលកិច្ចល្អ

៣.២ លើកកម្ពស់កិច្ចសម្របសម្រួល និងសហការជាមួយអ្នកពាក់ព័ន្ធនានា

៣.៣ បង្កើនសមត្ថភាពធនធានមនុស្ស

៣.៤ បង្កើនសមត្ថភាពស្ថាប័ន និងច្បាប់

៣.៥ បង្កើនសមត្ថភាពបច្ចេកវិទ្យា ព្រមទាំងយន្តការទទួលបច្ចេកវិទ្យា ផ្លាស់ប្តូរបច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យា

៣.៦ បង្កើនសមត្ថភាពហិរញ្ញវត្ថុឱ្យមាននិរន្តរភាព។

**មធ្យោបាយសម្រាប់គាំទ្រការអនុវត្តៈ** ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាព និងបានជោគជ័យ ក្របខ័ណ្ឌសាស្ត្រនេះត្រូវអនុវត្តន៍ដូចខាងក្រោម៖

១. បង្កើនចំណេះដឹងស្តីពីផ្នែកជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចិរភាព ដល់គណៈកម្មាធិការ អន្តរស្ថាប័នតាមរយៈការងារបច្ចេកទេសអន្តរក្រសួង

២. លើកកម្ពស់ និងបង្កើនការចូលរួម និងបង្កើនកំលាំង និងមធ្យោបាយឈ្នះៗ

៣. ការចងក្រងឯកសារបទពិសោធន៍ការងារថ្នាក់ជាតិ និងថ្នាក់តំបន់

៤. កំណត់សកម្មភាពជាអាទិភាពសម្រាប់អនុវត្ត

៥. ការកំណត់ និងប្រើប្រាស់ការលើកទឹកចិត្តដល់អ្នកអនុវត្តសកម្មភាព

៦. បញ្ចូលលក្ខខណ្ឌនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ទៅក្នុងការវាយតំលៃផលប៉ះពាល់បរិស្ថាន

៧. គោរពតាមគោលការណែនាំនានាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា

៨. ស្វែងយល់ពីគោលបំណង និងសកម្មភាពដែលបានកំណត់នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រ

៩. ជម្រុញការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា

១០. ត្រួតពិនិត្យ តាមដាន និងរាយការណ៍រាល់សកម្មភាពទាំងអស់

# ១. សាវតា

## ១.១ ស្ថានភាពប្រព័ន្ធតំបន់ការពារធម្មជាតនៅក្នុងប្រទេសកម្ពុជា

១. ប្រព័ន្ធតំបន់ការពារធម្មជាតិ[†]នៅក្នុងប្រទេសកម្ពុជាមានប្រមាណជា២៦ភាគរយ នៃផ្ទៃដីប្រទេសក្នុងនោះផ្ទៃដីចំនួន២ភាគ៣ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ហើយផ្ទៃដីនៅសល់ប្រមាណជា១ភាគ៣ ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. ប្រព័ន្ធតំបន់ការពារធម្មជាតិ ទាំងនេះមានដូចខាងក្រោម ៖

(ក) តំបន់ឧទ្យានជាតិ ចំនួន៧កន្លែង ក្នុងនោះមានតំបន់ការពារធម្មជាតិតាមឆ្នេរសមុទ្រចំនួន៤កន្លែង ដែនជម្រកសត្វព្រៃចំនួន១០កន្លែង តំបន់ការពារទេសភាពចំនួន៣កន្លែង តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣កន្លែង(មួយកន្លែងជាតំបន់ឆ្នេរសមុទ្រ)។ តំបន់ទាំងនេះស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន

(ខ) តំបន់ព្រៃការពារចំនួន៦កន្លែង និងតំបន់ដែនជម្រកត្រីចំនួន៨កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣. ដោយសារតែតំបន់ការពារធម្មជាតិគ្របដណ្តប់ជាង ១ភាគ៤ នៃផ្ទៃប្រទេស និងផ្តល់កម្រៃខាងសេដ្ឋកិច្ចខ្ពស់នោះ ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានប្រើប្រាស់ជាតំបន់ដែលរួមចំណែកដល់ការអភិវឌ្ឍន៍ ឬជាតំបន់ដែលមានអាទិភាពក្នុងការវិនិយោគ។ តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានានៅកម្ពុជាកំពុងតែចាប់ផ្តើមមានការទទួលស្គាល់ពីតំលៃរបស់វាតាមវិស័យនីមួយៗ។

៤. នៅឆ្នាំ២០០៤ សន្និសីទ ស្តីពីអនុសញ្ញាជីវៈចម្រុះ (CBD) នៃប្រទេសភាគីដែលក្នុងនោះប្រទេសកម្ពុជាជាសមាជិកយ៉ាងសកម្មដែរនោះ បានអនុម័តកម្មវិធីការងារតំបន់ការពារធម្មជាតិក្នុងគោលបំណង "កាត់បន្ថយឲ្យបានច្រើនបំផុត នៃអត្រានៃការបាត់បង់ជីវៈចម្រុះថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងជម្រុញឲ្យការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព"។ របាយការណ៍ស្តីពីតំបន់ការពារធម្មជាតិ [1] ដែលប្រទេសកម្ពុជាក៏បានដាក់ចូលអនុសញ្ញា ស្តីពីជីវៈចម្រុះនៅឆ្នាំ២០១០បានបង្ហាញថាគោលដៅ និងសកម្មភាពនានានៃកម្មវិធីការងារនេះទើបតែបានចាប់ផ្តើម ឬមិនទាន់បានចាប់ផ្តើមនៅឡើយ។

---

[†] [In Cambodia] [In this document], the term "protected area system" means (i) protected areas (terminology referring to those areas listed in Article 7 of the 2008 Protected Area Law that are under the jurisdiction of the Ministry of Environment (MoE) i.e. national parks, wildlife sanctuaries, protected landscapes, multiple use areas, Ramsar sites, biosphere reserves, natural heritage sites, and marine parks), and (ii) protection forests protected, inundated or flooded areas, (marine or freshwater) fishery conservation areas, fishery protected areas and fish sanctuaries under the jurisdiction of the Ministry of Agriculture, Forestry and Fisheries (MAFF), and referred to hereafter as conservation areas.

៥, នៅឆ្នាំ២០១០រដ្ឋភាគី នៃអនុសញ្ញាអន្តរជាតិ ស្តីពីជីវៈចម្រុះបានឯកភាពក្នុងការអភិរក្សឲ្យបាន ១៧ភាគរយ នៃតំបន់ដែនដីគោក និងទឹក ហើយ១០ភាគរយជាតំបន់ឆ្នេរសមុទ្រ និងសមុទ្រត្រឹមឆ្នាំ២០២០ ជាពិសេសតំបន់ដែលមានតំលៃជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ីតាមរយៈការគ្រប់គ្រងអេកូឡូស៊ីឲ្យមានប្រសិទ្ធភាព និងសមធម៌។ ប្រព័ន្ធតំបន់ការពារធម្មជាតិទាំងនេះត្រូវតែមានទំនាក់ទំនងគ្នាមិនអាចខ្វះបាន និងវិធានការអភិរក្សដែលមានប្រសិទ្ធភាព ដោយផ្អែកលើស្ថានភាពជាក់ស្តែង និងការធ្វើសមាហរណកម្មទៅក្នុងតំបន់ដីគោក និងតំបន់ទឹក។ ប្រទេសទាំងនេះបានឯកភាពគ្នាដូចនេះនៅក្នុងកិច្ចប្រជុំលើកទី១០ ដែលបានធ្វើឡើងនៅក្នុងទីក្រុង Nagoya ប្រទេសជប៉ុន នៅខែតុលា ឆ្នាំ២០១០ ដែលត្រូវបានចាត់ទុកថាជាទិសដៅជីវៈចម្រុះ Aichi ទី១១ នៃផែនការយុទ្ធសាស្ត្រ២០១១-២០២០[2]ដែលជាយុទ្ធសាស្ត្រមួយត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ដើម្បីធានាថាធនធានធម្មជាតិនៅលើពិភពលោកត្រូវបានការពារដែលជាផ្នែកមួយ នៃការប្រឹងប្រែងសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព កាត់បន្ថយភាពក្រីក្រ និងសុខុមាលភាពនៃជីវិតទាំងអស់នៅលើភពផែនដី។

៦, ដើម្បីសម្រេចទិសដៅផែនទីបង្ហាញផ្លូវនេះ គឺមានតួនាទីអនុវត្តកម្មវិធីការងារសម្រាប់តំបន់ការពារធម្មជាតិ សេចក្តីសម្រេចនិងដំណោះស្រាយមួយចំនួនដែលបានអនុម័តក្រោមអនុសញ្ញានៃជីវៈចម្រុះ និងអនុសញ្ញានានាពាក់ព័ន្ធនឹងជីវៈចម្រុះជាពិសេស អនុសញ្ញាមរតកពិភពលោក និងអនុសញ្ញារាំសាស្តីពីតំបន់ដីសើម។

៧, បើទោះបីជា តំបន់ដីគោក និងតំបន់ទឹកប្រទេសកម្ពុជាមានចំនួន ២៦ភាគរយ ត្រូវបានកំណត់ថាជាតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាក៏ដោយ ក៏នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។ ហើយក្នុងចំណោមកិច្ចការទាំងនេះរួមមាន កម្ពុជាចាំបាច់ត្រូវធ្វើឲ្យមានការរីកចម្រើនថែមទៀតលើកិច្ចការការពារតំបន់សមុទ្រ និងតំបន់ឆ្នេរសមុទ្រការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព នៃការធ្វើផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយផ្អែកលើស្ថានភាពជាក់ស្តែង ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការគំរាមកំហែងនានាដូចជាការប្រែប្រួលអាកាសធាតុ ពង្រឹងធនធានមនុស្សធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពនិងពង្រឹងស្ថានប័នដើម្បីឱ្យបំពេញមុខងារឲ្យកាន់តែមានប្រសិទ្ធភាពសម្រាប់អនុវត្តសកម្មភាពសំខាន់ៗដែលចាំបាច់។

៨, បច្ចុប្បន្នប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជាកំពុងទទួលរងសំពាធយ៉ាងខ្លាំង។ ដូច្នេះការបង្កើតតំបន់ការពារធម្មជាតិថ្មីៗក៏ត្រូវប្រឈមនឹងឧបសគ្គយ៉ាងច្រើន បើទោះបីជាប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះបានអនុម័តច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ព្រមទាំងគោលដៅ និងផែនការសំខាន់ៗជាច្រើនទៀតមានជាអាទិ៍ ផែនការជាតិសម្រាប់អភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលកំណត់ពីគោលនយោបាយ និងក្របខ័ណ្ឌ ដើម្បីការពារធនធានធម្មជាតិ និងការគ្រប់គ្រងឱ្យ

មានប្រសិទ្ធភាព នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា។ តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សភាគច្រើន (ចំនួន ៨៤%) ពុំទាន់គ្រប់គ្រងមានប្រសិទ្ធិភាពនូវឡើយទេ ដោយសារតែកង្វះផែនការគ្រប់គ្រង សមត្ថភាពស្ថាប័ននៅមានកម្រិត កង្វះចំណេះដឹងបច្ចេកទេស និងកង្វះព័ត៌ថ្មីៗអំពីជីវៈចម្រុះដែលចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេចចិត្តដោះស្រាយបញ្ហានានា ដូចជាការកាប់ឈើដោយគ្មាននិរន្តរភាព ការអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម និងការជួញដូរសត្វព្រៃខុសច្បាប់។ បញ្ជីលម្អិតស្តីពីឧបសគ្គដល់ការអភិវឌ្ឍន៍ និងការអនុវត្តនៃផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ១។

៩. សូមបញ្ជាក់ថា ឧបសគ្គដល់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិឲ្យមានប្រសិទ្ធភាពនៅកម្ពុជាមានដូចជាការត្រួតស៊ីគ្នានៃមុខងារ និងទំនួលខុសត្រូវក្នុងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាក់ទងទៅនឹងការការពារ និងអភិរក្សសត្វព្រៃ ការគ្រប់គ្រងព្រៃឈើ និងការអនុវត្តច្បាប់[3] ព្រមទាំងកង្វះខាតមន្ត្រីជំនាញ និងថវិកាដែលកត្តាទាំងនេះធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចិរភាព និងគ្រងបរិស្ថានឲ្យមានប្រសិទ្ធភាព។

១០. ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍អនុសញ្ញាជីវៈចម្រុះលេខ១៨៖[4]
"ផែនការគ្រប់គ្រង គឺជាក្របខ័ណ្ឌការងាររយៈពេលវែងដែលបង្ហាញ និងគ្រប់គ្រងកម្រិតនៃការប្រើប្រាស់ការអភិវឌ្ឍន៍ទីតាំងរូបវន្តចាំបាច់នានា ចំណុចអទិភាពសម្រាប់ការស្រាវជ្រាវ និងអន្តរាគមន៍ទៅនឹងការគំរាមកំហែងលើតំបន់ការពារធម្មជាតិ និងទិសដៅអភិរក្សនៃតំបន់ទាំងនេះ។ ផែនការគ្រប់គ្រងដែលមានប្រសិទ្ធភាពបំផុត គឺជាផែនការយុទ្ធសាស្ត្រទូលំទូលាយ ដែលត្រូវបញ្ចូលនូវភាពចាំបាច់ សម្រាប់ការអភិរក្សទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ផែនការគ្រប់គ្រង គឺជាយន្តការគន្លឹះ ក្នុងនោះបានបញ្ចូលលទ្ធផលពីការធ្វើផែនការតំបន់ដែលត្រូវបានកែប្រែទៅជាផែនការសកម្មភាពនៅមូលដ្ឋាន និងធ្វើការវាស់វែងពីផែនការការងារ និងថវិការប្រចាំឆ្នាំជាក់លាក់ ដោយធ្វើការប្រៀបធៀបនឹងការរីកចម្រើននៃការងារ។ ផែនការគ្រប់គ្រងចាំបាច់ត្រូវមានភាពអាចបត់បែនបានឲ្យបានច្រើន ដើម្បីសម្របទៅតាមកាលៈទេសៈ ដែលកំពុងតែប្រែប្រួល ប៉ុន្តែក្នុងពេលជាមួយគ្នានោះដែរក៏បាន ផ្តល់នូវសុវត្ថិភាពផ្លូវច្បាប់ និងលើផ្នែកគ្រប់គ្រងដើម្បីជាប្រទីបដល់ការធ្វើការសម្រេចចិត្តរយៈពេលវែងលើការវិនិយោគ ការរៀបចំការគ្រប់គ្រងធនធានមនុស្ស។ ផែនការដែលល្អបំផុតជាទូទៅត្រូវតែមានភាពច្បាស់លាស់ និងងាយស្រួលតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការចំណាយជាអតិបរមា និងធានាថាមានការយល់ដឹងទូលំទូលាយលើផែនការទាំងនេះ។

១១. នៅក្នុងបរិបទប្រទេសកម្ពុជា ប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានប្រសិទ្ធភាពមិនត្រឹមតែការពារធនធានសំខាន់ៗព្រមទាំងជាតំបន់ដែលមានតម្លៃផ្នែកអេកូឡូស៊ី និងជីវៈចម្រុះ ដូចជាប្រព័ន្ធព្រៃឈើ ភ្នំ ឆ្នេរសមុទ្រ និងទឹកសាប តែថែមទាំងផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងជន

ជាតិដើមភាគតិច[‡] ដែលពឹងអាស្រ័យយ៉ាងខ្លាំងទៅលើធនធានធម្មជាតិនៅតំបន់ការពារធម្មជាតិ។ ត្រូវចងចាំថាជីវៈចម្រុះនៅក្នុងប្រភេទអេកូឡូស៊ី តំបន់ការពារធម្មជាតិ តំបន់អភិរក្សនានា បណ្ដាញតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងរួមគ្នា ដើម្បីចៀសវាងការគ្រប់គ្រងដោយឡែកពីគ្នា។ ដើម្បីគ្រប់គ្រងតំបន់ទាំងនេះឲ្យប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់ ផែនការគ្រប់គ្រងយុទ្ធសាស្ត្រ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សត្រូវតែមាន ដែលមានចែងនៅក្នុងមាត្រា១៥ និងច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ២០០៨ ហើយផែនការនេះអាចជាគោលការណ៍ណែនាំដ៏ល្អបំផុតនិងអាចធានាឲ្យមានការប្រើប្រាស់ឲ្យមានប្រសិទ្ធផលបំផុត នៃស្ថានប័នជាតិ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិបានកំណត់ថាក្របខ័ណ្ឌដូចជា គោលការណែនាំ រចនាសម្ព័ន្ធ និងផែនការអាទិភាពរបស់រដ្ឋាភិបាលផ្សេងៗទៀតដែលជាជំហានដំបូង ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ នូវផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រ។

## ១.២ គោលបំណង នៃក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាតិ

១២. គោលបំណង នៃក្របខ័ណ្ឌយុទ្ធសាស្ត្រ គឺជាគោលការណ៍ដ៏ល្អរយៈពេលវែងដែលមានចែងពីវិធីសាស្ត្រ និងមធ្យោបាយដើម្បីដោះស្រាយឧបសគ្គ ក្នុងការបង្កើតតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សថ្មីៗដែលមានសម្ពាធខ្លាំងនាពេលបច្ចុប្បន្ន និងអនាគតភាពពីការគំរាមកំហែងនានាលើតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាជាធរមាន និងជាឧបសគ្គដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់នេះ។ ពិសេសជាងនេះទៀតនោះ ក្របខ័ណ្ឌយុទ្ធសាស្ត្រនឹងជាមាគ៌ាដល់ដំណើរការសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ព្រមទាំងជាមធ្យោបាយ សម្រាប់ការអនុវត្តតំបន់ទាំងនេះ។ ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រនេះ គឺជាឧបករណ៍មួយ ដូចមានចែងនៅក្នុងជំពូក៥ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ដែលត្រូវរៀបចំឡើងដោយក្រសួងបរិស្ថានសម្រាប់ឲ្យមានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា។ហើយផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រនេះ នឹងជួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិសម្រាប់ការរៀបចំផែនការសកម្មភាពនៅតំបន់ការពារធម្មជាតិនិងតំបន់អភិរក្សនីមួយៗនិងបណ្ដាញរបស់តំបន់ទាំងនេះនៅក្នុងប្រទេស។

១៣. ក្របខ័ណ្ឌយុទ្ធសាស្ត្របានរៀបចំឡើងក្នុងគោលបំណងដាក់បញ្ចូលនូវវិស័យនានា ដែលមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដោយផ្ទាល់ និងប្រយោលទៅលើតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាព្រមទាំងបណ្ដាញតំបន់ទាំងនេះនៅកម្ពុជា។ អាស្រ័យហេតុនេះក្របខ័ណ្ឌនេះធ្វើការយកចិត្តទុកដាក់ដល់គោលដៅយុទ្ធសាស្ត្រ គោលនយោបាយផែនការ និង កម្មវិធីសំខាន់ៗរបស់ប្រទេស

[‡‡] This term is used in the 2008 Protected Area Law.

សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្រដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០) និងគោលដៅ និងគោលនយោបាយជាតិមួយចំនួនទៀតដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយជាតិប្រជាជន។ ដូច្នេះក្របខ័ណ្ឌនេះអាចចាត់ទុកជាឯកសារយោង និងបរិបទរួម ចម្រុះវិស័យដែលក្នុងនោះត្រូវបន្សុីគ្នា ទៅនឹងការអនុវត្ត យុទ្ធសាស្ត្រនៅតាមវិស័យក្នុងពេលផ្តល់ការណែនាំដល់ការរៀបចំផែនការការធ្វើរចនាការបង្កើត ការគ្រប់គ្រង និងការត្រួតពិនិត្យតំបន់ការពារធម្មជាតិ តំបន់អភិរក្សនានា និងបណ្តាញតំបន់ទាំងនេះនៅថ្នាក់ជាតិ។

១៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះគួរជំរុញឲ្យមានសកម្មភាពពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងនោះមិនត្រឹមតែក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិចដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ព្រមទាំងសង្គមស៊ីវិលដោយរួមទាំងមនុស្សទាំងអស់ដែលជាអ្នកទទួលផលប្រយោជន៍ពីតំបន់ទាំងនេះ។

១៥. អាស្រ័យហេតុនេះហើយបានជា ក្របខ័ណ្ឌយុទ្ធសាស្ត្រត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ និងការអនុវត្តនូវគោលនយោបាយ និងផែនការតាមវិស័យនាននឹងវិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ីគោលការណ៍សំខាន់ៗរបស់ Addis Ababa ដែលជាគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ ជីវៈចម្រុះប្រកបដោយចិរភាព គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព (កំពុងតែរៀបចំ) និងកិច្ចព្រមព្រៀងថ្នាក់អន្តរជាតិ និងតំបន់ ដែលកម្ពុជាគឺជារដ្ឋភាគី។ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក៏រួមចំណែកដល់ការបង្កើតទំនាក់ទំនង ដែលមានសមត្ថភាពក្នុងការទាក់ទាញការយកចិត្តទុកដាក់ និងចូលរួមពីជាមួយដៃគូរផ្សេងៗទៀត ហើយជាលទ្ធផលជួយសម្រួលដល់ការបញ្ចូលតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាក្នុងរបៀបវារៈទូលំទូលាយនៅថ្នាក់តំបន់ និងថ្នាក់ជាតិអំពីធនធានធម្មជាតិ។

១៦. ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

(ក) គឺយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាក្នុងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាដោយធានាឲ្យមានភាពចុះសម្រុងគ្នាខាងផែនការ និងគោលនយោបាយក្នុងចំណោមក្រសួង វិស័យ និងស្ថាប័នពាក់ព័ន្ធ។ ជាលទ្ធផល ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ និងជួយបង្កើនថាមពលរួបរួមក្នុងការសម្របសម្រួលថ្នាក់ជាតិ កិច្ចសហប្រតិបត្តិការ និងគ្រប់គ្រងថ្នាក់តំបន់ដែលផែនការនេះអាចនាំឆ្ពោះទៅកាន់ការអនុវត្តការរៀបចំថវិកា និងការរៀបចំរបាយការណ៍ជាលក្ខណៈប្រព័ន្ធឲ្យកាន់តែទូលំទូលាយ និងជៀសវាងការប្រើប្រាស់វិធីសាស្ត្រដោយឡែកៗពីគ្នាក្នុងការការពារ និងការប្រើប្រាស់ធនធានជាតិប្រកបដោយចិរភាព[5] ដើម្បីសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងពេលបច្ចុប្បន្ន និងនៅពេលអនាគត។

(ខ) គឺមានលក្ខណៈទូលំទូលាយ និងបានបញ្ចូលតំបន់អភិរក្សគ្រប់ប្រភេទទាំងអស់ដែលមាននៅក្នុងប្រព័ន្ធ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សក្នុងប្រទេសកម្ពុជាតាមរបៀបមួយដែលបំពេញគ្នាទៅវិញទៅមក និងទទួលបានប្រយោជន៍ពីការបំពេញគ្នាទៅវិញទៅមក។

១៧. ក្រៅពីការរៀបចំ និងអនុវត្តផែនការតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ក្របខ័ណ្ឌយុទ្ធសាស្ត្រក៏គ្របដណ្តប់លើទិដ្ឋភាពតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ ដែលរួមចំណែកដល់ការរៀបចំបង្កើតតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាក្នុងប្រទេសកម្ពុជា។ ហើយប្រព័ន្ធតំបន់ការពារធម្មជាតិនេះដោយមានសំពាធយ៉ាងខ្លាំងទាំងពេលបច្ចុប្បន្ន និងអនាគតពិសេសការប្រែប្រួលអាកាសធាតុ និងធានាឲ្យមានការការពារប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃនូវធនធានធម្មជាតិរបស់ប្រទេស និងផ្តល់សេវានៃប្រព័ន្ធអេកូឡូស៊ី។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះមានចក្ខុវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

## ២. ចក្ខុវិស័យ

១៨. គឺថាប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា រួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ប្រកបដោយចិរភាពក្នុងនោះរួមទាំងការកាត់បន្ថយភាពក្រីក្រ ពិសេសតាមរយៈការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព នូវធនធានជីវៈចម្រុះ ធម្មជាតិ វប្បធម៌ និងសេវាប្រព័ន្ធអេកូឡូស៊ី។

## ៣. បេសកម្ម

១៩. បេសកម្មនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ គឺផ្តល់នូវការណែនាំសំខាន់ដល់ ៖

(ក) ផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិ សម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបានរៀបចំ និងអនុវត្តដើម្បីធានាឈានទៅសម្រេចបាន នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពប្រសិទ្ធផល និងស្មើរភាពគ្នាបំផុតនៃតំបន់ទាំងអស់នៅកម្ពុជា

(ខ) បើអាចធ្វើបានត្រូវពង្រីកប្រព័ន្ធតំបន់ការពារធម្មជាតិ ព្រមទាំងការបង្កើតតំបន់ច្រករបៀងអេកូឡូស៊ី នៅកន្លែងចាំបាច់ដើម្បីបំពេញលក្ខខណ្ឌអេកូឡូស៊ីនៃបណ្តាញប្រព័ន្ធតំបន់ការពារធម្មជាតិព្រមទាំងការតភ្ជាប់ជាមួយតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា និងរួមបញ្ចូលយ៉ាងទូលំទូលាយនៃដែនគោក និងដែនសមុទ្រ ពិសេសបញ្ហាប្រឈមមុខនៃការប្រែប្រួលអាកាសធាតុ

(គ) បង្កើនជាអតិបរមានៃផលប្រយោជន៍បរិស្ថាន និងសេដ្ឋកិច្ចសង្គមតាមគ្រប់រូបភាពពីជីវៈចម្រុះនៅតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា

២០. ដោយផ្អែក លើយុទ្ធសាស្ត្រជីវៈចម្រុះ និងផែនការសកម្មភាពជាតិ (NBSAP) ដែលទើបតែបង្កើតនាពេលថ្មីៗ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ គោលនយោបាយ និងច្បាប់ពាក់ព័ន្ធ គោលដៅ

អភិវឌ្ឍន៍ជាតិ និងការប្តេជ្ញាចិត្តនានាដែលពាក់ព័ន្ធទាំងនីថ្នាក់តំបន់ និងអន្តរជាតិ ក្របខ័ណ្ឌយុទ្ធសាស្ត្រជំរុញជាពិសេសនូវការធ្វើផែនការដែលចូលរួមមាន ការគ្រប់គ្រងចំណេះដឹង ការបង្កើនវិនិយោគទុន ការកសាងសមត្ថភាព និងសមិទ្ធផលនៃទិសដៅជីវៈចម្រុះទី៨ និងទិសដៅជីវៈចម្រុះផ្សេងៗទៀត ដែលបានអនុម័តបច្ចុប្បន្នភាព NBSAP ក្នុងប្រទេសកម្ពុជា។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ក៏នឹងអាចធ្វើជាមូលដ្ឋាន សម្រាប់បង្កើតវិធានទំនាក់ទំនងសម្រាប់បង្កើនចំណេះដឹង និងទាក់ទាញអ្នកពាក់ព័ន្ធ ផ្សេងៗទៀតហើយជាលទ្ធផលសម្រួលដល់ការដាក់បញ្ចូលតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទៅក្នុងរបៀបវារៈតាមវិស័យ និងជាតិទូលំទូលាយ និងលើកកម្ពស់ភាពរលូន និងកម្លាំងទ្វេរក្នុងចំណោមក្រសួង/ស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិលដែលទាក់ទងទៅនឹងតំបន់ការពារធម្មជាតិ និងតំបន់ អភិរក្សនានាព្រមទាំងសហគ្រាសរដ្ឋ និងឯកជនដែលទទួលផលប្រយោជន៍ពីតំបន់ទាំងនេះ ឬបង្កផលប៉ះពាល់តំបន់ទាំងនេះ។

## ៤. គោលបំណងយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ

២១. សកម្មភាពទាំងអស់ ដែលត្រូវអនុវត្តដើម្បីធានាថា តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងនេះឆ្លើយតបទៅនឹងគោលបំណង នៃការបង្កើតតំបន់ទាំងនេះ ចាំបាច់ត្រូវវាយតម្លៃជាប្រចាំពី ស្ថានភាព និងនិន្នាការ មុខងារ តួនាទី និងតំលៃ ការគំរាមកំហែងនិងសម្ពាធ និងផលប៉ះពាល់ពីវិធានការដើម្បីដោះស្រាយការគំរាមកំហែង និងសំពាធ។ ព័ត៌មាន ដែលបានមកពីការវាយតំលៃនេះនឹងជាផែនទីបង្ហាញផ្លូវ សម្រាប់ជ្រើសរើសសកម្មភាព និងពេលវេលាសមស្របបំផុតសម្រាប់បញ្ចូលទៅក្នុងផែនការសកម្មភាព ព្រមទាំងកំណត់ពីតំរូវការចាំបាច់ សម្រាប់បង្កើនសមត្ថភាពធនធានមនុស្ស ស្ថាប័ន បច្ចេកវិទ្យា និងហិរញ្ញវត្ថុ ដើម្បីអនុវត្តន៍សកម្មភាពទាំងនេះឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ដូច្នេះក្របខ័ណ្ឌយុទ្ធសាស្ត្រ នេះមានគោលបំណង យុទ្ធសាស្ត្រដែលទាក់ទងទៅនឹងមូលដ្ឋានចំណេះដឹង សម្រាប់ធ្វើការសម្រេច ផែនការសកម្មភាព និងចំណេះដឹងផ្នែកបរិស្ថាន។

### ៤.១ គោលបំណងយុទ្ធសាស្ត្រទី១ ៖ មូលដ្ឋានចំណេះដឹងសម្រាប់ធ្វើការសម្រេចចិត្ត

ពង្រឹងចំណេះដឹងអំពីបណ្តាញជាតិ នៃប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់ធ្វើការសម្រេច តាមរយៈការវាយតម្លៃ ការបង្កើនចំណេះដឹង ការរៀបចំព័ត៌មានផ្សព្វផ្សាយ និងការបង្កើនចំណេះដឹងអំពីតួនាទី តំលៃ និងលក្ខខណ្ឌចាំបាច់នានា នៃតំបន់ការពារធម្មជាតិ តំបន់អភិរក្សនានា និងបណ្តាញតំបន់របស់តំបន់ទាំងនេះនៅកម្ពុជា។

*<u>សកម្មភាពសំខាន់ៗ</u>*

១.១ ការវាយតម្លៃទិដ្ឋភាពសំខាន់ៗ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ក្នុងនោះរួមទាំងទំហំ និងទីតាំង ភាពចន្លោះប្រហោងអេកូឡូស៊ីក្នុងតំបន់ទាំងនោះ តំលៃ និងសារៈប្រយោជន៍នៃតំបន់ច្រករបៀង និងបញ្ចូលគ្នាតំបន់ដែនគោក និងសមុទ្រ ប្រព័ន្ធគ្រប់គ្រង តើការគ្រប់គ្រងទាំង

នោះត្រូវបានធ្វើឡើងតាមរយៈផែនការគ្រប់គ្រងដែលបានអនុម័ត ឬយ៉ាងណា ប្រសិទ្ធភាព និង សមធម៌ នៃការគ្រប់គ្រងតំបន់ទាំងនេះ តម្រូវការសមត្ថភាពចាំបាច់ កត្តានានា ដែលគំរាមកំហែង ដល់តំបន់ និងឧបសគ្គ នៃការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព នយោបាយបរិស្ថាន ជីវៈចម្រុះ និង និរន្តភាពនៃថវិកា។

១.២ បង្កើនការយល់ដឹង បង្កើតរៀបចំព័ត៌មានដោយមានមូលដ្ឋានទិន្នន័យមានលក្ខណៈងាយស្រួល ដល់អ្នកប្រើប្រាស់ស្តីពីមុខងារ តួនាទី តំលៃ និងលក្ខខណ្ឌតម្រូវទាំងអស់ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សជាលក្ខណៈពិសេសនៃតំបន់នីមួយៗ និងជាបណ្តាញរួមមួយក្នុងប្រទេសកម្ពុជា។

១.៣ បង្កលក្ខណៈឲ្យអាចប្រើប្រាស់/រកបានយ៉ាងទូលំទូលាយ នូវព័ត៌មានពាក់ព័ន្ធ នឹងសេចក្តីសម្រេច និងបង្កើនការយល់ដឹង។

## ៤.២ គោលបំណងយុទ្ធសាស្ត្រទី២ ៖ ផែនការសកម្មភាព

បង្កើនការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ស្របតាមទិសដៅជីវៈចម្រុះ Aichi ទី១១ និងទិសដៅ ពាក់ព័ន្ធនានា នៃទិសដៅជីវៈចម្រុះជាតិ ២០១១-២០២០ និង យុទ្ធសាស្ត្រជីវៈចម្រុះ និងផែនការ សកម្មភាពជាតិ ឆ្នាំ២០០២ ដែលបាននឹងកំពុងកែសម្រួលដើម្បីអនុវត្តទិសដៅជីវៈចម្រុះជាតិ ឆ្នាំ ២០១១-២០២០។ ដូច្នេះកម្ពុជា ត្រូវខិតខំប្រឹងប្រែងដើម្បីឈានទៅសម្រេចទិសដៅទាំងនេះ ដែលនៅពេលបច្ចុប្បន្នមានភាពយឺតយ៉ាវ ក្នុងការអនុវត្តកម្មវិធីការងារស្តីពីតំបន់ការពារធម្មជាតិ ដែលបានអនុម័តក្រោមអនុសញ្ញាជីវៈចម្រុះ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដែលបានកំណត់ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងអនុសញ្ញាផ្សេងៗទៀត ដែលកម្ពុជាបានផ្តល់ សច្ចាប័នក្នុងនោះរួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ អនុសញ្ញាមរតក ពិភពលោក និងអនុសញ្ញារ៉ាំសារ ស្តីពីតំបន់ដីសើម។

*<u>សកម្មភាពសំខាន់ៗ</u>*

ត្រូវចងចាំនូវភាពចាំបាច់មួយចំនួនដូចខាងក្រោម ៖

១.១ ធ្វើឲ្យសម្រេចនូវការអភិរក្ស នៃសេវាជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី នៅក្នុងប្រព័ន្ធតំបន់ការពារ ធម្មជាតិ ការស្តារឡើងវិញតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ដែលបានរងការរេចរឹល និងកំពុង រេចរឹល ឬទីតាំងនានាក្នុងតំបន់ទាំងនេះដែលបានរេចរឹល និងកំពុងរេចរឹល ការទប់ស្កាត់ និងបង្រ្កាប សកម្មភាពល្មើស និងប្រភេទរុក្ខជាតិរាតត្បាតពីខាងក្រៅ និងការប្រើប្រាស់ប្រកបដោយចីរភាព នៃ ធនធានធម្មជាតិ និងសេវាប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សស្របតាម មាត្រា១៦.១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨

១.២ ទោះបីជាការគ្រប់គ្រងដាច់ដោយឡែក ឬរួមក៏ដោយ ត្រូវតែបង្កើនការចូលរួមវិភាគទាននៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាដែលស្របតាមគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចិរភាព ក្នុងនោះរួមទាំងការកាត់បន្ថយភាពក្រីក្រ និងសុខុមាភាពជាតិនៅទូទាំងប្រទេស។

វាជាការចាំបាច់ណាស់ដើម្បីរៀបចំ និងអនុវត្តផែនការសកម្មភាព សម្រាប់តំបន់ការពារធម្មជាតិ តំបន់អភិរក្សនីមួយៗ និងបណ្តាញតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងមូលនៅកម្ពុជាដែលនឹងមានបញ្ចូលនូវរបៀប និងមធ្យោបាយដូចខាងក្រោម ៖

២.១ ជាកិច្ចការចាំបាច់ត្រូវថែរក្សា និងស្តារឡើងវិញនូវប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានស្រាប់

២.២ ការកំណត់និងបង្កើតតំបន់តំបន់ការពារធម្មជាតិថ្មីនិងប្រភេទតំបន់អភិរក្សនានាដែលរួមមាន ៖

(i) តំបន់ពិសេសទាំងឡាយណា ដែលមានសារៈសំខាន់ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោកផ្នែកជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ី

(ii) តំបន់ទាំងឡាយណាដែលជាមរតកធម្មជាតិ និងវប្បធម៌ និង

(iii) តំបន់ទាំងឡាយណាដែលជាតំណាងឲ្យអេកូឡូស៊ី

២.៣ បង្កើនការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

២.៤ ជានាឲ្យមានសមធម៌ក្នុងដំណើរការធ្វើការសម្រេចចិត្ត និងការចែករំលែក ផលប្រយោជន៍ដោយផ្តោតជាពិសេសចំពោះក្រុមប្រជាជនដែលងាយរងគ្រោះបំផុត

២.៥ ធានាការភ្ជាប់ និងការបញ្ចូលគ្នានៃតំបន់ទៅក្នុងតំបន់ដីគោក និងសមុទ្រ

២.៦ ដាក់បញ្ចូលតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាទៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយតាមវិស័យ (ដូចជាការអភិរក្សក្នុងការកាត់បន្ថយការបំភាយឧស្ម័នបណ្តាលមកពីការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD+) ការចំណាយសម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬគោលនយោបាយអំពីទេសចរណ៍ ការគ្រប់គ្រងធនធានទឹក ព្រៃឈើ មច្ឆជាតិ កសិកម្ម ថាមពល ដឹកជញ្ជូន ការប្រែប្រួលអាកាសធាតុ អភិវឌ្ឍន៍បៃតង គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៅកម្ពុជា

២.៧ អនុវត្តលិខិតបទដ្ឋាន និងច្បាប់ពិសេសៗ ពីកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ។

បើទោះបីជាតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ត្រូវយកចិត្តទុកដាក់បង្កើតឡើងបន្ទាប់ពីការវិភាគពីចំណុចខ្វះខាត បង្ហាញយ៉ាងច្បាស់ពីតម្រូវការ នៃការបង្កើតនោះក៏ដោយក៏ការពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផល នៃការគ្រប់គ្រងគួរតែជាសកម្មភាពមួយក្នុងចំណោមសកម្មភាពអទិភាពទាំងអស់។

**៤.៣ គោលបំណងយុទ្ធសាស្ត្រទី៣ ៖ សមត្ថភាពផ្នែកបរិស្ថាន**

ពង្រឹងសមត្ថភាពផ្នែកបរិស្ថានតាមរយៈការពង្រីកឲ្យទូលំទូលាយ នៃអភិបាលកិច្ចល្អ ការបង្កើនការចូលរួម ការលើកកម្ពស់កិច្ចសម្របសម្រួល និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងតំបន់ និងពង្រឹងសមត្ថភាពធនធានមនុស្ស ស្ថាប័ន បច្ចេកវិទ្យា និងហិរញ្ញវត្ថុប្រកបដោយចិរភាព។

*<u>សកម្មភាពសំខាន់ៗ</u>*

៣.១ បង្កើនការចូលរួម និងពង្រឹងអភិបាលកិច្ចល្អ

៣.២ លើកកម្ពស់កិច្ចសម្របសម្រួល និងសហការជាមួយអ្នកពាក់ព័ន្ធនានា

៣.៣ បង្កើនសមត្ថភាពធនធានមនុស្ស

៣.៤ បង្កើនសមត្ថភាពស្ថាប័ន និងច្បាប់

៣.៥ បង្កើនសមត្ថភាពបច្ចេកវិទ្យា ព្រមទាំងយន្តការទទួលបច្ចេកវិទ្យា ផ្លាស់ប្តូរបច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យា

៣.៦ បង្កើនសមត្ថភាពហិរញ្ញវត្ថុឱ្យមាននិរន្តរភាព។

២២. សកម្មភាពសំខាន់ៗដែលមាននៅក្នុងគោលបំណងយុទ្ធសាស្ត្រទាំង៣នេះ គឺមានទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយផែនការគ្រប់គ្រងដែលចាំបាច់ត្រូវរៀបចំធ្វើបច្ចុប្បន្នភាព និងអនុវត្តសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ។ ការអនុវត្តដែលមានប្រសិទ្ធភាពត្រូវស្ថិតនៅក្រោមការចង្អុលបង្ហាញពីគោលការណ៍ និងវិធីសាស្ត្រដែលប្រទេសកម្ពុជាបានអនុម័តនៅក្នុងយុទ្ធសាស្ត្រ និងគោលដៅជាតិ និងក្រោមកិច្ចព្រមព្រៀងពហុភាគីស្តីពីបរិស្ថាន។

២៣. គោលការណ៍ទាំងនេះ ជាមធ្យោបាយពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីឈានទៅដល់សម្រេចគោលបំណងជាយុទ្ធសាស្ត្រនិងចក្ខុវិស័យ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ហើយយើងត្រូវអនុវត្តដូចខាងក្រោម ៖

ក. វិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ី[6] គឺការគ្រប់គ្រងសមស្រប និងតាមបែបសមាហរណកម្មហើយមានតម្លាភាព ដោយសារតែមានការចូលរួម និងការចូលរួមពីភាគីពាក់ព័ន្ធនានា

ខ. គោលការណ៍ Addis Ababa គឺជាសេចក្តីណែនាំសម្រាប់ការប្រើប្រាស់ជីវៈចម្រុះប្រកបដោយចិរភាពដែលរួមមានធនធានជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ី[7]

គ. គោលការណ៍ នៃការទប់ស្កាត់ជាមុន[8]

ឃ.ការលើកទឹកចិត្តតាមរយៈការប្រើប្រាស់ធនធានសេនេទិចប្រកបដោយសមធម៌ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់ជីវៈចម្រុះ

ឃ. ចំណេះដឹង និងការសម្រេចចិត្តដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ

ង. ការគោរពសហគមន៍មូលដ្ឋាន និងចំណេះដឹងជាប្រពៃណី

ច.ការពិគ្រោះយោបល់ និងការសម្របសម្រួល (មាត្រា១៨នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ២០០៨) និង
ង. ទំនាក់ទំនង ការអប់រំផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងជាសារធារណៈ។

## ៥. មធ្យោបាយសម្រាប់គាំទ្រការអនុវត្ត

២៤. ដើម្បីការអនុវត្តឲ្យមានប្រសិទ្ធភាព និងបានជោគជ័យ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះត្រូវអនុវត្តន៍ដូចខាងក្រោម ៖

ក. បង្កើនចំណេះដឹងស្តីពីផ្នែកជីវៈចម្រុះ និងការអភិវឌ្ឍន៍ប្រកបដោយចិរភាពរួមទាំងការកាត់បន្ថយភាពក្រីក្រ ក្នុងចំណោមគណៈកម្មាធិការអន្តរស្ថាប័ន និង/ឬអន្តរក្រសួង ដែលបានបង្កើតឡើងសម្រាប់សម្រេចចិត្តសកម្មភាពសហប្រត្តិបត្តិការនៅថ្នាក់ជាតិ។ គណៈកម្មាធិការទាំងនេះរួមមានគណៈកម្មាធិការជាតិ សម្រាប់គោលនយោបាយគ្រប់គ្រងព្រៃឈើ គណៈកម្មាធិការជាតិតំបន់ឆ្នេរសមុទ្រ គណៈកម្មាធិការអភិវឌ្ឍន៍ក្រុង និងខេត្ត និងគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយទំនាស់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។ គណៈកម្មាធិការទាំងនេះ គឺជាអ្នកគាំទ្រយ៉ាងសំខាន់ក្នុងការអនុវត្តសកម្មភាព និងឈានទៅសម្រេចគោលបំណងដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ។ គណៈកម្មាធិការអន្តរក្រសួងស្តីពីជីវៈចម្រុះត្រូវបានស្នើឲ្យបង្កើតឡើងក្នុងបរិបទនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ដើម្បីសម្របសម្រួលសកម្មភាពក្រោមអនុសញ្ញាជីវៈចម្រុះពិសេសការអនុវត្ត ផែនការសកម្មភាព និងយុទ្ធសាស្ត្រទាំងនេះ។ ស្រដៀងគ្នានេះដែរ គណៈកម្មាធិការ អន្តរក្រសួងសម្រាប់ តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា គួរតែត្រូវបានបង្កើតឡើងដោយផ្អែកលើគំរូរបស់ក្រុមការងារ ដែលបានបង្កើតឡើងដោយក្រសួងបរិស្ថាន នៅឆ្នាំ២០០៥ ដែលមានតំណាងមកពីក្រសួងយ៉ាងតិចចំនួនបួន (ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងទេសចរណ៍) ដើម្បីការពារតំបន់ព្រៃរបោះនៅតំបន់ទន្លេមេគង្គក្រោម។

ខ. លើកកម្ពស់ការចូលរួម ពីសំណាក់ក្រុមអ្នកពាក់ព័ន្ធនានា ក្នុងនោះរួមទាំងការទទួលស្គាល់ពីតំលៃនៃការចូលរួម និងការបង្កើនកម្លាំង និងមធ្យោបាយឈ្នះៗ ដែលជាលទ្ធផលនៃការចូលរួមនេះ។ មាត្រា ២៩ នៃច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ២០០៨ ចែងថា ប្រជាពលរដ្ឋ ព្រះសង្ឃ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានមានករណីកិច្ចចូលរួមការពារអភិរក្ស និងស្តារធនធានធម្មជាតិឡើងវិញក្នុងតំបន់ការពារធម្មជាតិ។ មានការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើម្បីទទួលស្គាល់តំលៃ នៃចំណេះដឹងជាប្រពៃណីរបស់ពួកគេព្រមទាំងបញ្ចូលតំលៃទាំងនេះ ទៅក្នុងវិទ្យាសាស្ត្រទំនើបក្នុងគោលបំណងដើម្បីជម្រុញការថែរក្សាប្រឌិត។ ជាងនេះទៅទៀតការចូលរួមពី អ្នកធ្វើជំនួញ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល

សម្រាប់ចូលរួម និងគាំទ្រសកម្មភាពនេះក៏មានសារៈសំខាន់ណាស់ដែរ។ វិធីសាស្ត្រដោយមានការចូលរួមមានចែងនៅក្នុងវិធីសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី និងគោលការណ៍ណែនាំជាច្រើនទៀត សម្រាប់អនុវត្តការងារតំបន់ការពារធម្មជាតិ។ ជាពិសេសកិច្ចសហប្រត្តិបត្តិការរវាងក្រសួងបរិស្ថាន និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើនកិច្ចសហការ នៃសកម្មភាពរបស់ខ្លួនទាក់ទងទៅនឹងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានានឹងមានសារៈសំខាន់ណាស់ សម្រាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនេះឲ្យបានជោគជ័យ។ ដូចមានបង្ហាញក្នុងរបាយការណ៍ជាតិលើកទីបួនស្តីពីអនុសញ្ញាជីវៈចម្រុះ "ការសហការធ្វើការងារយ៉ាងជិតស្និទ្ធរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាសំខាន់សម្រាប់ធានាសុខុមាលភាព នៃបណ្តាញតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានានៅក្នុងប្រទេសកម្ពុជា។

គ. ការចងក្រងបទពិសោធន៍ការងារថ្នាក់ជាតិ និងថ្នាក់តំបន់ពោលគឺភាពជោគជ័យ និងបរាជ័យនៅគ្រប់ផ្នែកទាំងអស់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាពិសេសទាក់ទងនឹងការបង្កើត និងការអនុវត្តផែនការគ្រប់គ្រង។ ឯកសារដែលបានចងក្រងទាំងនេះ អាចប្រើសម្រាប់រៀបចំគោលការណែនាំ ឬធ្វើការកែសម្រួលការណែនាំដែលមានស្រាប់ ស្របទៅតាមស្ថានភាពប្រទេសកម្ពុជា។ យោងតាមមាត្រា ១៩ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ គោលការណ៍ណែនាំទាំងនេះគួរមានផែនការ បែបបទការងារ ការបង្កើតការគ្រប់គ្រង និងការត្រួតពិនិត្យតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា និងដំណើរការដែលមានបទដ្ឋានមួយសម្រាប់រៀបចំផែនការសកម្មភាពរបស់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ។ ការចងក្រងឯកសារទាំងនេះក៏អាចជួយដល់ការរៀបចំផែនការគំរូមួយ នៃតំបន់ការពារធម្មជាតិ/តំបន់អភិរក្សនានា ដែលមានចំណុចទាំងអស់ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ ដូចជាការគ្រប់គ្រងភ្លើងឆេះព្រៃ ការអភិរក្សសត្វព្រៃ និងការគ្រប់គ្រងសហគមន៍ការពារធម្មជាតិ និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ។ ដោយផ្អែកទៅលើការវាយតំលៃពីតម្រូវការទាំងនេះ ឯកសារទាំងនេះក៏អាចជួយរៀបចំ និងអនុវត្តន៍យុទ្ធសាស្ត្រនេះដើម្បីកៀងគរធនធានដោយប្រើប្រាស់យន្តការហិរញ្ញវត្ថុជាផ្លូវការ និងប្រកបដោយការផ្ទេរប្រឱតជាពិសេសមូលនិធិតំបន់ការពារធម្មជាតិនិងមូលនិធិអភិវឌ្ឍន៍ជាតិសម្រាប់វិស័យព្រៃឈើដែលមានមានចែងនៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២។ ដូច្នេះការរៀបចំផែនការធុរកិច្ច ដែលក្នុងនោះមានទាំងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាត្រូវបានទទួលស្គាល់ និងមានផែនការដោយចាត់ទុកជាធនធានអភិវឌ្ឍន៍យ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចសង្គម និងអាចធានាដល់ការកៀងគរធនធានដែលចាំបាច់ និងការប្រើប្រាស់ធនធាន ដែលកៀរគរឱ្យបានសមស្រប និងមានប្រសិទ្ធភាព

ឃ. ដោយយោងតាមភាពបន្ទាន់ ឬភាពចាំបាច់នៃសកម្មភាព និងឱកាសដែលមានក្នុងពេលបច្ចុប្បន្នសកម្មភាពជាអាទិភាពត្រូវតែកំណត់ ដើម្បីប្រើប្រាស់ធនធានដែលមានកំណត់ទាំងនេះឱ្យមានប្រសិទ្ធភាព

ង. ការកំណត់ និងប្រើប្រាស់ការលើកទឹកចិត្តដល់អ្នកអនុវត្តសកម្មភាពដែលមានរៀបរាប់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

ច. បញ្ចូលលក្ខខណ្ឌនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទៅក្នុងការវាយតំលៃផលប៉ះពាល់បរិស្ថាន និងគោលការណែនាំស្តីពីការវាយតំលៃបរិស្ថានក្នុងសកម្មភាពនានាក្នុងវិស័យណាដែលអាចប៉ះពាល់ដល់តួនាទីនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានាដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងគោលការណ៍ណែនាំស្តីពីជីវៈចម្រុះរួមទាំងការវាយតំលៃផលប៉ះពាល់បរិស្ថានដោយរាជរដ្ឋាភិបាល ដោយផ្អែកទៅតាមអនុសញ្ញាស្តីពីជីវៈចម្រុះ និង អនុសញ្ញារាំសា

ឆ. គោលការណែនាំដែលមានចែងនៅក្នុងកម្មវិធីការងារតំបន់ការពារធម្មជាតិ យោងតាមអនុសញ្ញាជីវៈចម្រុះ និងការណែនាំដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងពហុភាគីស្តីពីបរិស្ថានពិសេសទិសដៅ Aichi នៃអនុសញ្ញាជីវៈចម្រុះ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងវាលរហោដ្ឋានកម្ម (UNCCD) អនុសញ្ញានៃក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) អនុសញ្ញារាំសាស្តីពីដីសើម អនុសញ្ញាស្តីពីពានិជ្ជកម្មអន្តរជាតិលើរុក្ខជាតិ និងសត្វព្រៃដែលជិតផុតពូជ (CITES) អនុសញ្ញាមរតកពិភពលោក (WHC) កម្មវិធីជីវៈមណ្ឌល និងមនុស្ស (MAB) និងកិច្ចព្រមព្រៀង ឆ្នាំ១៩៩៥ស្តីពីកិច្ចសហប្រត្តិបត្តិការ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៅអាងទន្លេមេគង្គ[9]

ជ. ស្វែងយល់ពីគោលបំណង និងសកម្មភាពដែលបានកំណត់ នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រនេះ និងបញ្ចូលគោលបំណង និងសកម្មភាពទាំងនេះទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ប្រទេសកម្ពុជាដែលទាក់ទងនឹងជីវៈចម្រុះ និងយុទ្ធសាស្ត្រផ្សេងៗទៀតដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ឈ. ជម្រុញការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធនានាដែលមានចែងនៅក្នុងមាត្រាទី១៨នៃច្បាប់តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨។ ហើយមាត្រាទី១៩នៃច្បាប់នេះក៏បានចែងថា គំរូកិច្ចព្រមព្រៀងស្តីពីការចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិ រវាងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាមួយនឹងសហគមន៍តំបន់ការពារធម្មជាតិ និងរូបវន្តបុគ្គល ឬនិតិបុគ្គល។ ចំណែកឯមាត្រាទី៣១វិញបានចែងថាក្រសួងបរិស្ថានត្រូវស្តារ និងការកែលំអបរិស្ថានឡើងវិញពិសេសតំបន់រេចរិលនៅក្នុងតំបន់ការពារធម្មជាតិ

ដោយមានកិច្ចសហការជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិច សហគមន៍តំបន់ការពារធម្មជាតិ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល

៣. ត្រួតពិនិត្យ និងរាយការណ៍រាល់សកម្មភាពទាំងអស់ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រដោយយោលទៅតាមតំរូវការ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិពិសេសរបាយការណ៍ជាតិលើកទីប្រាំក្រោមអនុសញ្ញាជីវៈចម្រុះ ការរួមចំណែកក្នុងកែសម្រួល របាយការណ៍លើកទីបួននៃទិដ្ឋភាពជីវៈចម្រុះពិភពលោក និងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ ក្របខ័ណ្ឌយុទ្ធសាស្ត្រថែមទាំងឱ្យពិចារណាថា ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រ សម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សគួរតែពិនិត្យឡើងវិញយ៉ាងតិចណាស់រាងរាល់ប្រាំឆ្នាំម្តង។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖

## បញ្ហាគោលនៃឧបសគ្គចំបងៗក្នុងការបង្កើត និងអនុវត្តផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស

ដោយផ្អែកលើរបាយការណ៍នៃការវាយតម្លៃ និងការកំណត់ចំនុចអាទិភាពសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (RAPPAM) របស់អង្គការ WWF សម្រាប់ប្រទេសកម្ពុជា[10] កិច្ចការជាអាទិភាពរបស់ប្រទេសកម្ពុជាសម្រាប់មូលនិធិ បរិស្ថានពិភពលោក និងគម្រោងមូលនិធិ STAR ទាំងប្រាំ ហើយឧបសគ្គសំខាន់ៗដែលមានក្នុងប្រព័ន្ធតំបន់ការពារ ធម្មជាតិមានដូចខាងក្រោម ៖

**(ក) មូលដ្ឋានចំណេះដឹង**

(១) ព័ត៌មានតិចតួចសម្រាប់ជួយគាំទ្រដល់ការធ្វើការសម្រេចចិត្ត ក្នុងនោះរួមទាំងព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅពេលបច្ចុប្បន្ន និងអនាគត និងបទពិសោធនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី

(២) ដូចបានលើកឡើងនៅក្នុងរបាយការណ៍វាយតម្លៃ ឆ្នាំ២០០៧ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអកាសធាតុ ការប្រែប្រួលអាកាសធាតុគឺជាការគម្រាមកំហែងមួយក្នុងចំណោមការគម្រាមកំហែងធ្ងន់ធ្ងរទាំងឡាយដល់ជីវៈចម្រុះ និងមុខងារនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា

**(ខ) អំពីការរីកចម្រើនក្នុងការអនុវត្តផែនការ**

(១) កម្មវិធីតិចតួច ឬកម្មវិធីដែលមានការគ្រប់គ្រងមិនសមស្របទាក់ទងនឹងការលើកកម្ពស់ការផ្សព្វផ្សាយអំពីតួនាទី និងភាពចាំបាច់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស រួមទាំងមុខងារនៃតំបន់ទាំងនេះ

(២) បញ្ហាក្នុងការគ្រប់គ្រងការដើរល្បាត

(៣) ការកំណត់តំបន់ និងការកំណត់ព្រំប្រទល់មិនច្បាស់លាស់ ឬមិនទាន់បានចប់រួចរាល់

(៤) សម្ពាធកាន់តែខ្លាំងឡើងលើតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងប្រព័ន្ធអេកូឡូស៊ីដោយសារតែកំណើនប្រជាជន ការធ្វើពាណិជ្ជកម្មពិភពលោក ដែលជាញឹកញាប់នាំឲ្យមានការដកហូតធនធានធម្មជាតិហួសកម្រិត (ដូចជាអនុផលព្រៃឈើ) ការពង្រីកការកាប់រានព្រៃឈើ និងសកម្មភាពកសិកម្ម និងការធ្វើនេសាទ ការកសាងផ្លូវ ទេសចរណ៍ ការពង្រីកក្រុង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម

(៥) សកម្មភាពខុសច្បាប់មួយចំនួនដូចជា ការកាប់ឈើ ការធ្វើនេសាទ ការប្រមាញ់សត្វព្រៃ និងការពង្រីកដីកសិឧស្សាហកម្មខ្នាតធំខុសច្បាប់

(៦) ជម្លោះជាមួយប្រជាជនមូលដ្ឋាន

**(គ)សមត្ថភាពបរិស្ថាន**

(១) ការគាំទ្រផ្នែកផ្លូវច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងការអនុវត្តច្បាប់មានភាពទន់ខ្សោយ

(២) កង្វះផែនការគ្រប់គ្រង

(៣) កង្វះការចូលរួម កិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជិតស្និទ្ធជាមួយនឹងសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ ក្នុងរួមទាំងវិស័យផ្សេងៗទៀតដែលស្ថិតនៅក្រៅជីវៈចម្រុះ

(៤) ឧបសគ្គសង្គម និងនយោបាយ

(៥) កង្វះធនធានហិរញ្ញវត្ថុ

(៦) កង្វះជំនាញបច្ចេកទេស និងធនធានមនុស្ស

**ឧបសម្ព័ន្ធ ២៖**

**ឧទាហរណ៍នៃឯកសារជាតសំខាន់ៗដែលបង្ហាញពីឱកាសក្នុងការបង្កើតតំបន់ការពារធម្មជាត**

| *ច្បាប់ជាតិ គោលដៅ ឬផែនការ* | *ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស* |
|---|---|
| ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ | ច្បាប់នេះកំណត់ពីក្របខ័ណ្ឌគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ការពារធម្មជាតិ ដែលក្របខ័ណ្ឌនេះក៏ក្របដណ្តប់លើតំបន់អភិរក្សផងដែរ។ |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ (NSDP) | ជំពូកទី ៤ (គោលនយោបាយ និងសកម្មភាពអាទិភាព ៖ ២០០៩-២០១៣) មានគោលនយោបាយជាអាទិភាពដែលគាំទ្រដល់ការបង្កើតតំបន់ការពារធម្មជាតិ និងតំបន់ព្រៃការពារក្នុងគោលបំណងដើម្បីអភិរក្សជីវៈចម្រុះ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅជនបទ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច |
| | "យាន្ត" ទាំងបីសម្រាប់កិច្ចអភិវឌ្ឍដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជា ការបង្វែរទិសដៅនៃការវិនិយោគពីតំបន់ទីប្រជុំជន ទៅកាន់ទីជនបទ វិមជ្ឈការប្រព័ន្ធនយោបាយ និងនីតិរដ្ឋផ្តល់ឱកាសឲ្យមានការទទួលស្គាល់ពីភាពចាំបាច់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ពោលគឺផលិតផល និងសេវារបស់តំបន់ទាំងនេះ ជាពិសេស សម្រាប់សេដ្ឋកិច្ចមូលដ្ឋាន និងជាផ្នែកមួយនៃវិស័យអភិវឌ្ឍន៍ដែលមានទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពជាមួយនឹងវិស័យផ្សេងៗទៀត[11]។ |
| កំណែទម្រង់កម្មវិធីព្រៃឈើ | កំណែទម្រង់នេះស្របទៅនឹងអាទិភាពគោលនយោបាយនៃរដ្ឋាភិបាលអាណត្តិទី ៤ ទាក់ទងនឹងការការពារ និងអភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដែលក្នុងនោះមានការស្នើឡើងពីការកំណត់ព្រំប្រទល់ និងការបែងចែកដីក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សទៅឲ្យសហគមន៍មូលដ្ឋាន។ |
| គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព | គោលដៅទាំងនេះត្រូវបានបង្កើតឡើងសម្រាប់ប្រើជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥។ គោលដៅទាំងនេះនឹងត្រូវមានបញ្ចូលផ្នែកអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន និងត្រូវយកទៅអនុវត្តនៅគ្រប់ប្រទេសទាំងអស់។ បន្ទាប់ពីមានការទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់នៃជីវៈចម្រុះនៅក្នុងការអភិវឌ្ឍន៍នៅក្នុង "*អនាគតដែលយើងចង់បាន*"[12] ឯកសារស្តីពីលទ្ធផលនៃសន្និបាតអង្គការសហប្រជាជាតិ អំពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (Rio + 20), សន្និបាតរដ្ឋភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះបានលើកទឹកចិត្តឱ្យភាគី និងដៃគូ ស្ថាប័ន អង្គការ និងដំណើរការពាក់ព័ន្ធទាំងអស់ធ្វើការពិចារណាបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់ជីវៈចម្រុះឆ្នាំ ២០១១-២០២០ និងទិសដៅជីវៈចម្រុះ Aichi ក្នុងនោះរួមទាំងទិសដៅជីវៈចម្រុះ Aichi ១១ ស្តីពីតំបន់ការពារធម្មជាតិក្នុងការរៀបចំរបៀបវារៈ អភិវឌ្ឍន៍អង្គការសហប្រជាជាតិបន្ទាប់ពីឆ្នាំ២០១៥ និងក្នុងដំណើរការនៃការបង្កើតគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព។ |

| ច្បាប់ជាតិ គោលដៅ ឬផែនការ | ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស |
|---|---|
| ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ | ជំពូកទី៣ស្តីពីនិរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ ជំពូកទី ៦ ស្តីពីព្រៃការពារ និង ជំពូកទី ១០ ស្តីពីការអភិរក្សសត្វព្រៃជំពូកទី ៩ ស្តីពីការគ្រប់គ្រងព្រៃសហគមន៍ ជំពូកទី ១២ ស្តីពីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។ល។ |
| ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦ | ការពិពណ៌នាអំពីវិស័យជលផលក្នុងជំពូកទី ៣ រួមមាននិយមន័យនៃបច្ចេកស័ព្ទ ដែលប្រើប្រាស់សម្រាប់តំបន់ការពារទឹកសាប និងទឹកប្រៃ។ ជំពូកទី ៤ និយាយពី គោលការណ៍ទាក់ទងនឹងការគ្រប់គ្រងសមស្រប រួមទាំងការអភិរក្សជលផល។ ជំពូកទី៥ និងទី ៦ បង្ហាញពីវិធីក្នុងការការពារ និងអភិរក្សជលផល ទាំងនៅក្នុង ទឹកសាប និងទឹកសមុទ្រជាពិសេសព្រៃលិចទឹក និងព្រៃកោងកាង។ |
| ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧ | មានទន្លេ និងទីជំរាលជាច្រើនដែលជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ និង តំបន់អភិរក្សនានា។ នៅមាត្រាទី១០នៃច្បាប់នេះបានបរិយាយថាក្រសួងធនធាន ទឹក និងឧតុនិយម មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងអាងទន្លេ អាង ទន្លេរង ទឹកលើទីជំរាល ទឹកក្រោមដី និងល្អាងទឹកក្រោមដីដោយសហការជាមួយ នឹងក្រសួងពាក់ព័ន្ធ។ ចំណែកឯមាត្រទី២៣ក៏បានកំណត់ថា ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬ ជាតំបន់ហាមឃាត់ការប្រើ ប្រាស់ទឹក ក្នុងករណីដែលទឹកលើទីជម្រាលដែលកំពុងរងការគំរាមកំហែងដោយ សកម្មភាពមនុស្ស ឬធម្មជាតិ។ |

***ឧបសម្ព័ន្ធ៣៖***

## ឧទាហរណ៍ពីសកម្មភាពជាក់លាក់ទាក់ទងនឹងការបង្កើត និងការអនុវត្តផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ

(ឧទាហរណ៍ទាំងនេះត្រូវបានយកមកពិចារណា និងពិភាក្សាក្នុងអំឡុងពេលនៃកិច្ចពិភាក្សាថ្នាក់ជាតិដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញនៅខែសីហា និងកញ្ញា ឆ្នាំ២០១៣)

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | **គោលបំណងយុទ្ធសាស្ត្រទី១ ៖ មូលដ្ឋានចំណេះដឹងសម្រាប់ធ្វើការសម្រេចចិត្ត**<br>ពង្រឹងចំណេះដឹងអំពីបណ្តាញជាតិ នៃប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់ធ្វើការសម្រេច តាមរយៈការវាយតម្លៃ ការបង្កើនចំណេះដឹង ការរៀបចំព័ត៌មានផ្សព្វផ្សាយ និងការបង្កើនចំណេះដឹងអំពីតួនាទី តំលៃ និងលក្ខខណ្ឌតម្រូវនានា នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា និងបណ្តាញតំបន់របស់តំបន់ទាំងនេះនៅកម្ពុជា។ | |
| | *១.១ ការវាយតម្លៃទិដ្ឋភាពសំខាន់ៗ នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស* | *វាយតម្លៃពីគុណតម្លៃនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សបច្ចុប្បន្ន*<br>នៅក្នុងប្រទេសកម្ពុជាការវាយតម្លៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនៅទូទាំងប្រទេសមិនត្រូវបានវាយតម្លៃនៅឡើយនោះទេដោយសារកង្វះសមត្ថភាពបច្ចេកទេស និងធនធានហិរញ្ញវត្ថុ។ ចំណេះដឹងទូលំទូលាយអំពីគុណតម្លៃនៃតំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារទាំងមូលរបស់ជាតិ អំពីរបៀបនៃតំបន់ទាំងនេះរួមចំណែកដល់ទ្រព្យសម្បត្តិ និងការរីកចម្រើនរបស់កម្ពុជាក្នុងនោះរួមទាំងការវាយតម្លៃពីសន្និធិកាបោនលើផែនដីដែលប្រព័ន្ធតំបន់ការពារធម្មជាតិស្រូបទុកនៅពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុអាចជម្រុញទឹកចិត្តភាគីទាំងអស់ ឲ្យធ្វើការធានាថាការគ្រប់គ្រងតំបន់ទាំងនេះមានប្រសិទ្ធភាពខ្ពស់។ អាស្រ័យហេតុនេះ ប្រទេសកម្ពុជាអាចសម្រេចថា នៅត្រឹមឆ្នាំ២០១៥ និងការពង្រឹងការងារដែលបានអនុវត្តរួចហើយនៅក្នុងប្រទេស គុណតម្លៃ (ការផ្តល់ការគ្រប់គ្រង ការគាំទ្រ និងគុណតម្លៃខាងវប្បធម៌ ដោយរួមទាំងការកំសាន្ត/ទេសភាព/ជំនឿ) នៃតំបន់ការពារធម្មជាតិ និងអភិរក្សទាំងអស់ត្រូវបានរៀបរាប់។ គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលដែលបានរៀបចំឡើងនៅក្រោមគំនិតផ្តួចផ្តើមសេដ្ឋកិច្ចនៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះអាចយកមកប្រើដើម្បីលើកកម្ពស់សមត្ថភាពចាំបាច់សម្រាប់ធ្វើការវាយតម្លៃ។ កិច្ចការនេះនឹង |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | រួចចំណែកដល់ភាពជោគជ័យនៃទិសដៅ១,[13] នៃជីវៈចម្រុះកម្ពុជាដែលបានអនុម័តនៅឆ្នាំ ២០១៣ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិ (យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះកម្ពុជា)។<br>*ការវាយតម្លៃលើប្រសិទ្ធភាពគ្រប់គ្រង*<br>នេះគឺជាការវាយតម្លៃពីស្ថានភាពនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងវិសាលភាពនៃការគ្រប់គ្រងដែលនឹងឈានទៅសម្រេចគោលដៅ និងគោលបំណងដែលបានកំណត់។ ការវាយតម្លៃនេះជាធម្មតាត្រូវបានធ្វើឡើងដើម្បីពិនិត្យបរិបទនៃតំបន់ទាំងនោះ (បរិស្ថាន) របៀបនៃការរៀបចំផែនការ និងគោលបំណងដែលបានឯកភាព ការបាត់ចែងធនធានមនុស្ស ហិរញ្ញវត្ថុ និងស្ថាប័ន ផែនការគ្រប់គ្រង (ដោយយោងលើលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រងទាំង៦ របស់ IUCN និងឧទាហរណ៍ សកម្មភាពក្នុងការទប់ស្កាត់ និងការកាត់បន្ថយបទល្មើស ការកំណត់ព្រំប្រទល់ ការគ្រប់គ្រងអ្នកទេសចរណ៍ ការស្តារទីតាំងឡើងវិញ ស្ថានភាពច្បាប់) និងលទ្ធផលនៃសម្មភាពគ្រប់គ្រង លទ្ធផលសម្រេច (ផលិតផល និងសេវាដែលបានបង្កើតឡើង ចំនួនជនល្មើសដែលបានចាប់ខ្លួនជាដើម) និងផលប៉ះពាល់លើតំបន់ការពារដូចជាលក្ខខណ្ឌល្អប្រសើរនៃប្រព័ន្ធអេកូឡូស៊ី (លទ្ធផលសម្រេច)។<br>នៅក្នុងប្រទេសកម្ពុជា ៖<br>▪ អង្គការ WWF បានប្រើប្រាស់វិធីសាស្ត្រនៃRAPPAM នៅឆ្នាំ ២០០៤ ដើម្បីវាយតម្លៃពីស្ថានភាពនៃតំបន់ការពារ និងអភិរក្សក្នុងប្រទេសកម្ពុជា។ អង្គការនេះបានធ្វើការកត់សម្គាល់ក្នុងកិច្ចពិគ្រោះយោបល់របស់ខ្លួនក្នុងចំណោមកិច្ចនានាថាឯកសារ "ស្តីពីការបង្កើតផែនការគ្រប់គ្រងដោយមានការចូលរួមសម្រាប់តំបន់ការពារធម្មជាតិ និងអភិរក្សក្នុងប្រទេសកម្ពុជា" គួរត្រូវបានធ្វើឲ្យចប់រាល់ការផ្សព្វផ្សាយ និងប្រើប្រាស់។<br>▪ នៅក្នុងឆ្នាំ ២០១០ របាយការណ៍ស្តីពីតំបន់ការពារធម្មជាតិត្រូវបានដាក់ជូន CBD ដោយប្រទេសកម្ពុជាបានធ្វើការកត់សម្គាល់ថា ប្រទេសនេះពុំមានការរីកចម្រើន ឬពុំទាន់បានចាប់ផ្តើមការងារស្តីពីការវាយតម្លៃ និងការកែលម្អនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទេ (គោលដៅ ៤.២ នៃកម្មវិធីការងារក្នុងតំបន់ការពារធម្មជាតិដែលបានអនុម័តដោយសន្និបាតភាគីនៃអនុសញ្ញាស្តីពីជីវចម្រុះ)<br>▪ ការវាយតម្លៃភ្លាមៗ/ត្រួសៗពីប្រសិទ្ធភាពនៃការគ្រប់គ្រង ដូចជា WWF Rapid Assessment and |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | Prioritization of Protected Areas Management (RAPPAM) គួរតែធ្វើឡើងក្នុងរយៈពេលទៀតទាត់ និងក្នុងចន្លោះពេលខ្លីពីការវាយតម្លៃមួយទៅការវាយតម្លៃមួយទៀត។ ការវាយតម្លៃដូចនេះអាចត្រូវបានរៀបចំផែនការសម្រាប់រយៈពេល ១០ឆ្នាំ បន្ទាប់ពីការវាយតម្លៃមុនដែលបានធ្វើឡើងក្នុងឆ្នាំ២០០៤។ វិធីសាស្ត្រវាយតម្លៃដែលមានលក្ខណៈលម្អិតជាងនេះគួរបានរៀបចំធ្វើឡើង ក្នុងរយៈពេលវែងជាងនេះ ដើម្បីប្រមូលទិន្នន័យលម្អិត និងគ្រប់ជ្រុងជ្រោយជាងការវាយតម្លៃរយៈពេលខ្លី អាស្រ័យលើមូលនិធិដែលមាន។ វិធីសាស្ត្រវាយតម្លៃទាំងឆាប់រហ័ស និងលម្អិតទាំងនេះនឹងជួយក្នុងការកំណត់ផែនការយុទ្ធសាស្ត្រទាក់ទងនឹងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងបណ្តាញតំបន់ទាំងនេះនៅថ្នាក់ជាតិដើម្បីឈានទៅសម្រេចគោលបំណងអភិរក្ស និងអភិវឌ្ឍន៍ជាតិ កាន់តែមានប្រសិទ្ធភាព និងច្បាស់លាស់។ ដូច្នេះប្រទេសកម្ពុជាអាចសម្រេចថា រហូតដល់ឆ្នាំ ២០១៥ ផែនការយុទ្ធសាស្ត្រដែលមានចែងនៅក្នុងច្បាប់ស្តីពីតំបន់ការពារឆ្នាំ ២០០៨ ត្រូវបានធ្វើចប់រួចរាល់ ហើយអាចសម្រេចលើការកសាងសមត្ថភាពលើការវាយតម្លៃនៃអនុសាស្ត្រអនុវត្តពីរបាយការណ៍ សម្រាប់ប្រទេសកម្ពុជា ដែលគួរដាក់បញ្ចូលនូវចំណុចទាំងឡាយដូចខាងក្រោម ៖<br>(ក) កាលវិភាគសម្រាប់ធ្វើការវាយតម្លៃឆាប់រហ័ស និងមានលក្ខណៈលម្អិតនៃប្រសិទ្ធភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស<br>(ខ) ផែនការសម្រាប់កំណត់បទដ្ឋាន មូលដ្ឋានទិន្នន័យ និងបទពិសោធអនុវត្តដែលបានឯកភាពគ្នាមួយចំនួនសម្រាប់វិធី សាស្ត្រគ្រប់គ្រង និងវិធីសាស្ត្រសម្រាប់ធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ដោយយកចិត្តទុកដាក់លើបទពិសោធន៍ថ្នាក់តំបន់<br>(គ) បង្កើតឲ្យមានយន្តការសម្រាប់ត្រួតពិនិត្យ និងរាយការណ៍អំពីតំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារធម្មជាតិទាំងមូល<br>(ឃ) ថវិកាដែលបានស្នើ ឬយុទ្ធសាស្ត្រយុទ្ធសាស្ត្រសម្រាប់កៀរគរធនធានហិរញ្ញវត្ថុសម្រាប់សកម្មភាពទាំងអស់នេះនិងវិធី និងមធ្យោបាយសម្រាប់កៀងគរមូលនិធិ និងធនធានផ្សេងៗដែលត្រូវការជាចាំបាច់។ |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | ១.២ បង្កើនការយល់ដឹង បង្កើត និងរៀបចំព័ត៌មានមូលដ្ឋានមានលក្ខណងាយស្រួលដល់អ្នកប្រើប្រាស់ ស្តីពីមុខងារ តួនាទី តំលៃ និងលក្ខខណ្ឌតម្រូវទាំងអស់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សជាលក្ខណៈពិសេសនៃតំបន់នីមួយៗ និងជាបណ្តាញរួមមួយក្នុងប្រទេស កម្ពុជា | ទិន្នន័យ និងព័ត៌មានដែលប្រមូលបានពីការវាយតម្លៃដែលមានរៀបរាប់នៅក្នុងសកម្មភាពសំខាន់ៗ ១.១ ខាងលើ គួររៀបចំដាក់បញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ ឬមូលដ្ឋានទិន្នន័យផ្ទាល់ខ្លួនដែលបានផ្សព្វផ្សាយនៅក្នុងយន្តការផ្សព្វផ្សាយព័ត៌មានថ្នាក់ជាតិដែលស្ថិតនៅក្រោមអនុសញ្ញាស្តីពីជីវៈចម្រុះ។ ការវាយតម្លៃទាំងអស់នេះអាច/នឹងជួយសម្រួលដល់ការបង្កើត និងអនុម័តបទដ្ឋាន លក្ខណៈវិនិច្ឆ័យ និងបទពិសោធអនុវត្តល្អៗសម្រាប់រៀបចំផែនការជ្រើសរើស បង្កើតការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ។ ការវាយតម្លៃទាំងនេះនឹងជួយដល់កិច្ចព្រមព្រៀងនានា ស្តីពីមូលដ្ឋានទិន្នន័យ និងត្រូវបានប្រើប្រាស់សម្រាប់ព្យាករណ៍ពីអនាគតនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សក្នុងប្រទេសកម្ពុជាទៅតាមសេណារីយ៉ូផ្សេងៗ។ ដូច្នេះប្រទេសកម្ពុជាត្រូវជានាថាត្រឹមឆ្នាំ ២០១៥ យន្តការផ្សព្វផ្សាយព័ត៌មានថ្នាក់ជាតិដែលបានបង្កើតឡើងតាមអនុសញ្ញាស្តីពីជីវៈចម្រុះត្រូវបានរៀបចំឡើងដើម្បីគ្រប់គ្រងទិន្នន័យ ឬដើម្បីភ្ជាប់ជាមួយនឹងមូលដ្ឋានទិន្នន័យដែលមានលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ក្នុងប្រទេសកម្ពុជា ក្នុងនោះរួមទាំងមូលដ្ឋានទិន្នន័យដែលអាចរកឃើញតាមប្រព័ន្ធអ៊ីនធើណិតដោយមូលដ្ឋានទិន្នន័យនេះជាផ្នែកមួយ នៃប្រព័ន្ធមូលដ្ឋានទិន្នន័យជីវៈចម្រុះជាតិដោយមានយន្តការសម្រាប់សម្រួលដល់ការដាក់បញ្ចូលទិន្នន័យ និងការប្រើប្រាស់ព័ត៌មាន។ ក្នុងពេលជាមួយគ្នានេះដែរការងារដែលត្រូវចាប់ផ្តើមរួចរាល់រួមមាន ៖<br>(ក) ធ្វើសំយោគព័ត៌មានដែលមាននៅក្នុងមូលដ្ឋានទិន្នន័យដោយរៀបចំឲ្យទៅជាទម្រង់របាយការណ៍ (ក្នុងនោះរួមទាំងការត្រួតពិនិត្យឡើងវិញពីគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា សម្រាប់របាយការណ៍ជាតិលើកទី៥ និងទី៦ (ដែលត្រូវផុតកំណត់ឆ្នាំ២០១៤) និងការបោះពុម្ពផ្សាយលើកទី៤ និងទី៥ នៃចក្ខុវិស័យជីវៈចម្រុះសកលលោក (GBO-4 and GBO-5)) និងសៀវភៅ ព្រមទាំងប័ណ្ណផ្សព្វផ្សាយសម្រាប់អ្នករៀបចំគោលនយោបាយ និងសេចក្តីសម្រេចសម្រាប់លើកកម្ពស់ការយល់ដឹងជាទូទៅ និង<br>(ខ) បង្កើតគោលការណ៍ណែនាំស្តីអំពីវិធីសាស្ត្រ និងមធ្យោបាយក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ព្រមទាំងបណ្តាញតំបន់ទាំងនេះឱ្យមានប្រសិទ្ធភាព ការបង្កើនសមត្ថភាពដោយផ្អែកលើករណីសិក្សាដែលបានជោគជ័យ និងបទពិសោធផ្សេងៗទៀត |

<table>
<tr><th></th><th>សកម្មភាពសំខាន់ៗ</th><th>សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន</th></tr>
<tr><td>២</td><td colspan="2">គោលបំណងយុទ្ធសាស្ត្រទី ២ ៖ ផែនការសកម្មភាព<br>បង្កើនការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ស្របតាមទិសដៅជីវៈចម្រុះAichi ទី១១ និងទិសដៅពាក់ព័ន្ធនានានៃផែនការយុទ្ធសាស្ត្រសម្រាប់ជីវៈចម្រុះ ២០១១-២០២០ ដែលត្រូវបានកែសម្រួល និងដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រជីវៈចម្រុះ និងផែនការសកម្មភាពជាតិ។ ត្រូវធ្វើការខិតខំប្រឹងប្រែងជាពិសេសដើម្បីឈានទៅសម្រេចទិសដៅទាំងនេះ ដែលនៅពេលបច្ចុប្បន្នមានភាពយឺតយ៉ាវ ក្នុងការអនុវត្តកម្មវិធីការងារស្តីពីតំបន់ការពារធម្មជាតិដែលបានអនុម័តក្រោមអនុសញ្ញាជីវៈចម្រុះ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងអនុសញ្ញាផ្សេងៗទៀត ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងនោះរួមទាំងអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាមរតកពិភពលោក និងអនុសញ្ញារ៉ាំសារ ស្តីពីតំបន់ដីសើម។</td></tr>
<tr><td></td><td>២.១ ជាកិច្ចការចាំបាច់ ត្រូវថែរក្សា និងស្តារឡើងវិញនូវប្រព័ន្ធតំបន់ការពារធម្មជាតិដែលមានស្រាប់</td><td>តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សជាច្រើនកន្លែងកំពុងរងសម្ពាធពីការគម្រាមកំហែងជាច្រើនប្រភេទ។ ការគម្រាមកំហែងទាំងនេះ ដែលការគម្រាមកំហែងមួយចំនួននាំដល់ការធ្លាក់ចុះគម្របនៃតំបន់ការពារធម្មជាតិ ក្នុងពេលការគម្រាមកំហែងមួយចំនួនទៀតប៉ះពាល់ដល់ប្រសិទ្ធភាពនៃតំបន់ ចាំបាច់ត្រូវដោះស្រាយ និងគ្រប់គ្រង។ ចំណុចដៅខាងក្រោមដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ សម្រាប់ឆ្នាំ២០១៥ គួរយកទៅអនុវត្ត ៖<br><br>▪ ចំណុចដៅ ៧.១ ៖ រក្សានូវគម្របព្រៃឈើក្នុងកម្រិត ៦០%<br>▪ ចំណុចដៅ ៧.២ ៖ រក្សានូវផ្ទៃដីតំបន់ការពារធម្មជាតិដែលមានចំនួន ២៣ ក្នុងកម្រិត ៣,៣ លានហិកតា នៅឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១៥<br>▪ ចំណុចដៅ ៧.៣ ៖ រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ ក្នុងកម្រិតបច្ចុប្បន្ន ១,៣៥ លានហិកតា ឲ្យនៅថេរដល់ឆ្នាំ ២០១៥<br><br>វាជាការចាំបាច់ក្នុងការបង្ហាញពីមូលហេតុនៃកិច្ចខិតខំប្រែបែងខាងលើនេះ ដោយបញ្ជាក់មិនត្រឹមតែភាពចាំបាច់នៃប្រព័ន្ធអេកូឡូស៊ីប៉ុណ្ណោះទេ តែថែមទាំងផលប្រយោជន៍សេដ្ឋកិច្ចសង្គមទាំងក្នុងពេលបច្ចុប្បន្ន និង/ឬទាំងនៅក្នុងពេលអនាគត។ ចំណុចដៅថ្មីៗទៀតត្រូវមានការឯកភាពដែលជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ប៉ុន្តែវាចាំបាច់ជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិដែលបានធ្វើបច្ចុប្បន្នភាព បន្ទាប់ពីបានអនុម័តផែនការយុទ្ធសាស្ត្រសម្រាប់ជីវៈចម្រុះ ឆ្នាំ ២០១១-២០២០ ដោយសន្និបាតភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះនៅក្នុងកិច្ចប្រជុំលើកទី១០ របស់ខ្លួន។ ចំណុច</td></tr>
</table>

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | ដៅថ្មីៗទាំងនេះនឹងត្រូវកំណត់ដោយផ្អែកលើការវាយតម្លៃពីស្ថានភាព និងនិន្នាការនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងលើការគម្រោងកំហែងដែលប៉ះពាល់លើតំបន់ទាំងនេះ។ |
| | *២.៣ បង្កើនការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល* | នៅក្នុងប្រទេសកម្ពុជា តំបន់ការពារធម្មជាតិត្រូវបានដាក់ជាក្រុមឡើងវិញទៅតាមលក្ខណវិនិច្ឆ័យទាំងបួនទាក់ទងនឹងលក្ខណវិនិច្ឆ័យគ្រប់គ្រងទាំងបួនរបស់ IUCN ៖ (i) ឧទ្យានជាតិ (ស្មើនឹងលក្ខណវិនិច្ឆ័យទីពីររបស់ IUCN), (ii) ដែនជម្រកសត្វព្រៃ (ស្មើនឹងលក្ខណវិនិច្ឆ័យទីបួនរបស់ IUCN ), (iii) តំបន់ការពារទេសភាព (ស្មើនឹងលក្ខណវិនិច្ឆ័យទីប្រាំរបស់ IUCN ) និង (iv) តំបន់ប្រើប្រាស់ច្រើនយ៉ាង (ស្មើនឹងលក្ខណវិនិច្ឆ័យទីប្រាំមួយរបស់ IUCN )។ តំបន់អភិរក្សដូចជាជម្រកត្រី និងព្រៃការពារក៏អាចត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខណវិនិច្ឆ័យខ្លះក្នុងចំណោមលក្ខណវិនិច្ឆ័យទាំងនេះ ជាពិសេស លក្ខណវិនិច្ឆ័យទី៥ និងទី៦ របស់ IUCN។ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ព័ត៌មានលម្អិតអំពីគោលបំណងនៃលក្ខណវិនិច្ឆ័យខុសៗទាំងនេះ ផ្តល់ការណែនាំយ៉ាងសំខាន់ទាក់ទងនឹងប្រភេទនៃការគ្រប់គ្រង។ សម្រាប់តំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សនីមួយៗ ដើម្បីឈានទៅសម្រេចគោលបំណងអភិរក្ស និងគោលបំណងផ្សេងៗទៀតសម្រាប់តំបន់ទាំងនោះចាំបាច់ត្រូវបង្កើតផែនការគ្រប់គ្រងដែលរៀបរាប់ពីសកម្មភាពជាក់ស្តែងនានា ដែលជាធម្មតាត្រូវបានបង្កើតឡើងជុំវិញផែនការ និងថវិកាជាក់លាក់ប្រចាំឆ្នាំ។ ផែនការការងារ និងថវិកាទាំងនេះអាចប្រើសម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលរីកចម្រើន ដូចមានកំណត់នៅក្នុងកថាខណ្ឌ ១០ខាងលើ។ ជាងនេះផែនការគ្រប់គ្រងទាំងនេះអាចជាការណែនាំ និងគ្រប់គ្រងកម្រិតប្រើប្រាស់ អភិវឌ្ឍន៍ធនធានចាំបាច់ ការស្រាវជ្រាវជាអាទិភាព និងអន្តរាគមន៍ដល់ការគំរាមកំហែងដល់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ព្រមទាំងចំណុចដៅអភិរក្សនៃតំបន់ទាំងនោះ។ នៅពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមានតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សចំនួន ៥ ប៉ុណ្ណោះដែលមានផែនការគ្រប់គ្រង។ ដោយសារកង្វះខាតក្នុងការកំណត់បទដ្ឋាន និងធនធានផ្សេងៗសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនោះ វិធីសាស្ត្រនានាត្រូវបានប្រើប្រាស់ដើម្បីបង្កើតផែនការគ្រប់គ្រងដែលមានស្រាប់តិចតួចប៉ុណ្ណោះ។ ដូច្នេះនៅក្នុងជំហានដំបូងនៅប្រទេសកម្ពុជាអាចធ្វើការត្រួតពិនិត្យឡើងវិញ នៅថ្នាក់ជាតិនូវផែនការគ្រប់គ្រងដែលមានស្រាប់សម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា ដើម្បីកំណត់ពីស្ថានភាពបច្ចុប្បន្ននៃតំបន់ទាំងនោះ |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | ជាពិសេសតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សដែលពុំមានផែនការគ្រប់គ្រង ឬតំបន់ដែលមានផែនការហួសពេលកំណត់។ បន្ទាប់ពីបានត្រួតពិនិត្យឡើងវិញលើផែនការទាំងនេះរួចហើយ ផែនការគ្រប់គ្រងគួរត្រូវបានធ្វើបច្ចុប្បន្នភាពតាមការចាំបាច់ដោយប្រើប្រាស់គោលការណ៍បច្ចេកទេសដែលនឹងត្រូវបង្កើតឡើងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨។ កថាខ័ណ្ឌ ៤២៤ នៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ២០០៩ - ២០១៣ បញ្ជាក់នៅក្នុងគោលនយោបាយជាអាទិភាព "ការយកចិត្តទុកដាក់ត្រូវធ្វើឡើងចំពោះការគ្រប់គ្រងតំបន់ការពារធម្មជាតិ"។មានការឯកភាពជារួមថាដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងចាំបាច់ត្រូវមានចំណុចទាំងឡាយ ដូចខាងក្រោមក្នុងចំណោមកិច្ចការផ្សេងៗទៀត ៖<br>▪ ផែនការគ្រប់គ្រងដែលមានគោលបំណងច្បាស់លាស់សម្រាប់តំបន់នីមួយៗដែលបានកំណត់នៅក្នុងតំបត់ការពារ ធម្មជាតិ ឬតំបន់អភិរក្ស ដោយយកចិត្តទុកដាក់លើវិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ី និងគោលការណ៍ Addis Ababa ដែលជាគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព និងដោះស្រាយសម្ពាធនៅពេលបច្ចុប្បន្ន និងអនាគតលើតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ជាពិសេសផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ តំបន់គ្រប់គ្រងចាំបាច់ត្រូវកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់ ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨។ តំបន់ការពារធម្មជាតិជាច្រើនកន្លែងកំពុងប្រឈមនឹងបញ្ហាក្នុងការឈានទៅឯកភាព ក្នុងការកំណត់ព្រំប្រទល់ជាក់ស្តែងនៃតំបន់ទាំងនោះ។ ជាងនេះទៀត គោលការណ៍លម្អិតសម្រាប់រៀបចំតំបន់ ត្រូវមានជាចាំបាច់ដើម្បីបង្កើតប្រព័ន្ធបែងចែកតំបន់សម្រាប់តំបន់ការពារ ឬតំបន់អភិរក្សនីមួយៗដោយផ្អែកលើជម្រកសត្វព្រៃ ប្រភេទសត្វព្រៃ និងព្រៃឈើ និងទម្រង់នៃការប្រើប្រាស់ដីរបស់សហគមន៍មូលដ្ឋាន និងបទប្បញ្ញត្តិនានាដែលនឹងគ្រប់គ្រងពីរបៀបប្រើប្រាស់តំបន់ខុសៗគ្នា[14]<br>▪ ប្រព័ន្ធត្រួតពិនិត្យសមស្រប និងល្បិតល្អន់ដើម្បីវាយតម្លៃពីការរីកចម្រើនឆ្ពោះទៅសម្រេចគោលបំណងនានា<br>▪ ធនធានហិរញ្ញវត្ថុ មនុស្ស និងបច្ចេកទេសគ្រប់គ្រាន់ រួមទាំងអភិបាលកិច្ចសមស្របក្នុងនោះរួមទាំងភាពជា |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសន្និទានភាពមួយចំនួន |
|---|---|---|
| | | ដៃគូរវាងរដ្ឋាភិបាល សហគមន៍មូលដ្ឋានផ្នែកឯកជន និងសង្គមស៊ីវិលនៅពេលចាំបាច់ និងអាចអនុវត្តបាន<br>▪ ការស្រាវជ្រាវវិទ្យាសាស្ត្រដើម្បីទទួលបានព័ត៌មាន និងទិន្នន័យចាំបាច់សម្រាប់ប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេច<br>▪ វិធី និងមធ្យោបាយសម្រាប់ចែករំលែកការចំណាយ និងផលប្រយោជន៍ប្រកបដោយសមធម៌ក្នុងចំណោមដៃគូនានា (សមធម៌ក្នុងការគ្រប់គ្រង)។<br>ផ្នែកមូលដ្ឋានសម្រាប់វាយតម្លៃប្រសិទ្ធភាពលើការគ្រប់គ្រងអាចត្រូវបានរៀបចំឡើងស្របតាមបរិបទ (ឧទាហរណ៍ ការគម្រាមកំហែង) ការរៀបចំផែនការ (ឧទាហរណ៍ គោលបំណងនៃតំបន់ការពារធម្មជាតិ) ធនធានដាក់បញ្ចូល (ឧ. ធនធានបុគ្គលិក) ដំណើរការ (ឧ. ការគ្រប់គ្រងទេសចរណ៍ ការស្តារទីតាំង) ប្រសិទ្ធផល (ឧ. ចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួន) និងលទ្ធផល (ឧ. ស្ថានភាពល្អប្រសើរនៃអេកូឡូស៊ី)[15]។ ការសិក្សាមួយចំនួនបង្ហាញពីកត្តាខាងក្រោមដែលជាកត្តាសំខាន់បំផុតសម្រាប់កំណត់ប្រសិទ្ធភាពនៃការគ្រប់គ្រង ៖ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ (មានការរៀបចំត្រឹមត្រូវ រួមទាំងមានព្រំប្រទល់ដែលបានកំណត់ត្រឹមត្រូវ) ការពង្រឹងច្បាប់មានប្រសិទ្ធភាព រួមទាំងដំណោះស្រាយក្នុងការកាន់កាប់ដីធ្លី ការបណ្តុះបណ្តាលបុគ្គលិក ការស្រាវជ្រាវ និងការត្រួតពិនិត្យ សន្តិសុខ និងភាពអាចទុកចិត្តបាននៃប្រភពផ្តល់មូលនិធិ ប្រសិទ្ធភាពរដ្ឋបាល ធនធានធម្មជាតិ និងសកម្មភាពការពារវប្បធម៌ កម្មវិធីប្រាស្រ័យទាក់ទង ការកសាង និងការថែទាំសមស្រប។ សមាសភាពទាំងនេះជាទូទៅមានសារៈសំខាន់សម្រាប់តំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សក្នុងប្រទេសកម្ពុជា។ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សគួរធ្វើការគោរពស្ថាប័ន និងច្បាប់ជាទំនៀមទម្លាប់នៃសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ការចូលរួមពាក់ព័ន្ធ (រដ្ឋាភិបាល សហគមន៍ ផ្នែកឯកជន និងសង្គមស៊ីវិល) ការបញ្ចូលនូវប្រព័ន្ធចំណេះដឹងជាប្រពៃណី និងវិទ្យាសាស្ត្រទំនើបសម្រាប់រៀបចំផែនទី ការប្រើប្រាស់ដីធ្លី និងការកំណត់តំបន់។ល។ និងសហគ្រប់គ្រង និងអភិបាលកិច្ចល្អ[16] គឺជាកត្តាដែលអាចធ្វើឲ្យការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាព។ ដោយផ្អែកលើសន្និបាតភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះដែលបានស្នើឡើងដោយភាគីទាំងអស់ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃការ |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | គ្រប់គ្រងឲ្យបាន ៦០%នៃតំបន់ការពារធម្មជាតិទាំងអស់នៅត្រឹមឆ្នាំ២០១៥[17]នោះ ប្រទេសកម្ពុជាត្រូវបង្កើតផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធការពារធម្មជាតិថ្នាក់ជាតិ និងការណែនាំបច្ចេកទេសសម្រាប់បង្កើត និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ (ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨) និងតំបន់អភិរក្ស និងសម្រាប់អនុវត្តផែនការទាំងនោះ។ ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រនេះអាចបង្កើតឡើងដោយផ្អែកលើការវាយតម្លៃលើការអនុវត្តអនុសាសន៍ពី RAPPAM, ក្នុងប្រទេសកម្ពុជា និងរួមបញ្ចូលនូវចំណុចនានាដូចខាងក្រោម ៖<br>(ក) កាលវិភាគសម្រាប់ធ្វើការវាយតម្លៃឆាប់រហ័ស និងការវាយតម្លៃល្អិតល្អន់ពីប្រសិទ្ធភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស<br>(ខ) ផែនការសម្រាប់កំណត់បទដ្ឋាន មូលដ្ឋានទិន្នន័យ និងបទពិសោធន៍ល្អៗដែលបានឯកភាពលើវិធីសាស្ត្រគ្រប់គ្រង និងវិធីសាស្ត្រដើម្បីធានាការគ្រប់គ្រងតំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិទាំងមូលឲ្យមានប្រសិទ្ធផល និងប្រសិទ្ធភាពដោយផ្អែកលើបទពិសោធថ្នាក់តំបន់<br>(គ) បង្កើតយន្តការសម្រាប់ត្រួតពិនិត្យ និងរាយការណ៍អំពីតំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធការពារធម្មជាតិថ្នាក់ជាតិ និង<br>(ឃ) សំណើរថវិកាសម្រាប់សកម្មភាពទាំងអស់ វិធី និងមធ្យោបាយសម្រាប់កៀងគរមូលនិធិ និងធនធានផ្សេងៗដែលត្រូវការ។<br>ក្រៅពីនេះ ប្រទេសកម្ពុជាអាចសម្រេចធ្វើការវាយតម្លៃឆាប់រហ័សពីប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់ការពារទាំងអស់ និងប្រព័ន្ធតំបន់ការពារនៅថ្នាក់ជាតិនៅក្នុងប្រទេស និងពិនិត្យពិចារណាលើលទ្ធផលសម្រាប់បង្កើតផែនការគ្រប់គ្រង។ |
| ៣ | គោលបំណងយុទ្ធសាស្ត្រទី៣ ៖ សមត្ថភាពផ្នែកបរិស្ថាន<br>ពង្រឹងសមត្ថភាពផ្នែកបរិស្ថានតាមរយៈការពង្រីកឲ្យទូលំទូលាយ នៃអភិបាលកិច្ចល្អ ការបង្កើនការចូលរួម ការលើកកម្ពស់កិច្ចសម្របសម្រួល និងកិច្ចសហការក្នុងចំណោមអ្នកពាក់ព័ន្ធទាំង ថ្នាក់ជាតិ និងតំបន់ និងពង្រឹងសមត្ថភាពធនធានមនុស្ស ស្ថាប័នបច្ចេកវិទ្យា និងហិរញ្ញវត្ថុប្រកបដោយចិរភាព | |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | *៣.១ បង្កើនការចូលរួម និងពង្រឹកអភិបាលកិច្ចល្អ* | នៅក្នុងកិច្ចខិតខំប្រឹងប្រែងពង្រឹកគំរូអភិបាលកិច្ចលើតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សក្នុងប្រទេសកម្ពុជា ពង្រឹកកម្លាំងរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានក្រោមឱវាទ (អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងរដ្ឋបាលព្រៃឈើ/រដ្ឋបាលជលផល ដែលទទួលខុសត្រូវតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន គួរបានពង្រឹង រួមទាំងការប្រមូលព័ត៌មាន និងទិន្នន័យស្រាវជ្រាវ។ ដូចមានកត់សម្គាល់នៅក្នុងរបាយការណ៍ថ្នាក់ជាតិលើកទី៤ ស្របតាមអនុសញ្ញាស្តីពីជីវៈចម្រុះ "ភាពជាដៃគូការងារយ៉ាងជិតស្និទ្ធរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាការចាំបាច់សម្រាប់សុខុមាលភាពនៃប្រព័ន្ធតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ"។ |
| | *៣.២ បង្កើនសមត្ថភាពហិរញ្ញវត្ថុឲ្យមាននិរន្តរភាព។* | កង្វះធនធានហិរញ្ញវត្ថុ គឺជាឧបសគ្គចំបងមួយដល់ការបង្កើតផែនការគ្រប់គ្រង និងការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ និងប្រព័ន្ធតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ។ ការកៀងគរធនធានរួមមាន ៖ (i) ការវាយតម្លៃពីតម្រូវការហិរញ្ញវត្ថុសម្រាប់តំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ និង (ii) ការកៀងគរធនធានពីប្រភពផ្សេងៗអាចចាត់ទុកជាការងារជាអាទិភាពជាយុទ្ធសាស្ត្រ។<br>*ប្រទេសកម្ពុជាអាច ៖*<br>▪ រៀបចំឲ្យមានកិច្ចប្រជុំតុមូលថ្នាក់អនុតំបន់ និងជាមួយអ្នកផ្តល់ជំនួយថ្នាក់ជាតិដែលពាក់ព័ន្ធនឹងស្ថាប័នផ្តល់មូលនិធិ ដោយសហការជាមួយនឹងគម្រោងគំនិតផ្តួចផ្តើម *LifeWeb Initiative*[18] ដើម្បីជួយដល់ការកៀងគរមូលនិធិសម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួនសម្រាប់តំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ ដោយប្រើប្រាស់ប្រភពមូលនិធិពីអនុសញ្ញា និងប្រភពមូលនិធិថ្មីៗ<br>▪ បង្កើតផែនការការងារសម្រាប់បណ្តាញនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សរបស់ខ្លួន ឲ្យស្របតាមវិស័យផ្សេងៗទៀត ដូចជាវិស័យទេសចរណ៍ (ដែលប្រទេសកម្ពុជាមានយុទ្ធសាស្ត្រលើវិស័យនេះ) និងអនុវត្តផែនការនោះ<br>▪ ធានាថាមូលនិធិដែលកៀងគរបានសម្រាប់ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ ក្រោមការបំពេញបន្ថែម |

| | សកម្មភាពសំខាន់ៗ | សកម្មភាព គោលដៅ និងសនិទានភាពមួយចំនួន |
|---|---|---|
| | | លើកទី ៥ និងទី៦ នៃមូលនិធិពិសេសរបស់មូលនិធិបរិស្ថានពិភពលោក បន្ថែមនឹងការគាំទ្រពីប្រភពផ្សេងៗទៀត ក្នុងនោះរួមទាំងមូលនិធិ ទាក់ទងនឹង *REDD+* ត្រូវប្រើប្រាស់ឲ្យបានសមស្រប និងឲ្យទាន់ពេលវេលា ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្តល់ហិរញ្ញវត្ថុសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស<br>▪ បង្វែរមូលនិធិដែលសល់ពីការប្រមូលមូលនិធិ *STAR-GEF-5* របស់ខ្លួនសម្រាប់ការប្រែប្រួលអាកាសធាតុ និងការរេចរឹលដី ទៅប្រើសម្រាប់គម្រោងតំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងប្រព័ន្ធការពារធម្មជាតិថ្នាក់ជាតិ ដែលអាចនឹងបានប្រយោជន៍ទ្វេ។ មូលនិធិ *STAR-GEF-5* របស់កម្ពុជាសម្រាប់ជីវៈចម្រុះដែលបានកៀរគរត្រូវបានប្រើប្រាស់ ហើយមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុនៅសល់ ចំនួន ១.៧១០.០០០ ដុល្លារ និងថវិកាសម្រាប់ការរេចរឹលដីនៅសល់ចំនួន ២០.០០០ ដុល្លារ។ ប្រសិនបើមូលនិធិនៅសល់ទាំងនេះមិនត្រូវបានកំណត់ជាអាទិភាពសម្រាប់ការប្រែប្រួលអាកាសធាតុ និងការរេចរឹលដីនៅឡើយ មូលនិធិទាំងនេះអាចយកទៅប្រើប្រាស់សម្រាប់លើកកម្ពស់តំបន់ការពារធម្មជាតិ តំបន់អភិរក្ស និងបណ្តាញតំបន់ទាំងនេះនៅថ្នាក់ជាតិ និងសម្រាប់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងជាលទ្ធផលលើកកម្ពស់ការស្តារ ដីដែលបានរេចរឹល និងរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (តាមរយៈការបំបែកការបូន) និងការបន្សាំ។<br>▪ ស្រាវជ្រាវរកប្រភពផ្សេងៗទៀតនៃធនធានហិរញ្ញវត្ថុ ដូចជា ការបង់ប្រាក់សម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី បន្ថែមទៅនឹងមូលនិធិពិសេសសម្រាប់តំបន់ការពារធម្មជាតិ ដែលមានចែងក្នុងច្បាប់ស្តីពីតំបន់កាពារធម្មជាតិ ឆ្នាំ ២០០៨។ មូលនិធិពិសេសសម្រាប់តំបន់ការពារធម្មជាតិនេះអាចត្រូវបានបង្កើតឡើងជាផ្នែកមួយនៃមូលនិធិពិសេសសម្រាប់ជីវៈចម្រុះ (មើលចំណុចដៅជីវៈចម្រុះ ២ របស់ប្រទេសកម្ពុជា ដែលស្មើនឹងចំណុចដៅជីវៈចម្រុះ *Aichi* ទី២០ )។ |

**ឧបសម្ព័ន្ធ ៤៖**

## ផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះផ្តល់ការណែនាំដូចខាងក្រោម៖

(ក) ជាដំបូងអំពីការបង្កើត និងការអនុវត្តផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់ការរៀបចំតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនានា និង

(ខ) សម្រាប់លើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រង និងការពង្រីកប្រព័ន្ធតំបន់ការពារក្នុងប្រទេសកម្ពុជា នៅពេលចាំបាច់

បន្ទាប់ពីមានការឯកភាពគ្នាលើក្របខ័ណ្ឌយុទ្ធសាស្ត្រពីសំណាក់គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ស្របតាមមាត្រា ១៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនឹងរៀបចំឲ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រនេះដោយសហការជាមួយនឹងដៃគូរបស់ខ្លួន និងចាប់ផ្តើមអនុវត្តផែនការ ដើម្បីឈានទៅសម្រេចគោលបំណងយុទ្ធសាស្ត្រដែលបានឯកភាពគ្នា។ ផែនការនេះនឹងមានសកម្មភាពជាក់លាក់មួយចំនួនដូចខាងក្រោម ៖

(ក) បង្កើត និងអនុវត្តផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ (តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស) (ជាពិសេសគោលបំណងយុទ្ធសាស្ត្រទី ១ និងទី ២)

(ខ) វិធី និងមធ្យោបាយដើម្បីធានា និងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងសម្រាប់ពង្រីកប្រព័ន្ធតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា នៅពេលចាំបាច់ (ជាពិសេសគោលបំណងយុទ្ធសាស្ត្រទី ២) និង

(គ) បញ្ហាអន្តរវិស័យរួមទាំងការចាប់ផ្តើមដំណើរការប្រមូលព័ត៌មានសម្រាប់ សកម្មភាពនីមួយៗដែលបានបញ្ជាក់នៅក្រោមគោលបំណងយុទ្ធសាស្ត្រដើម្បីកំណត់មូលដ្ឋានទិន្នន័យសម្រាប់ប្រៀបធៀបជាមួយនឹងការរីកចម្រើន (ជាពិសេសគោលបំណងយុទ្ធសាស្ត្រទី ១ និងទី៣)។

១. <u>ការបង្កើត និងការអនុវត្តផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ (តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស)</u>

<u>ចំណុចដៅ ៖</u> បញ្ចប់ឲ្យបានរួចរាល់នូវផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំតំបន់ការពារធម្មជាតិ និងដាក់ឲ្យអនុវត្តនៅឆ្នាំ ២០១៤

<u>សនិទានភាព ៖</u>

(ក) កថាខ័ណ្ឌ ៤២៤ នៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ បញ្ជាក់ក្នុងចំណោមគោលនយោបាយជាអាទិភាពថា “ការគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវការបន្តការយកចិត្តទុកដាក់ខ្ពស់”

(ខ) បទប្បញ្ញត្តិនៃជំពូក ៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

(គ) ក្នុងចំណោមតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ មានតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សចំនួន៥ ប៉ុណ្ណោះដែលមានផែនការគ្រប់គ្រង ប៉ុន្តែផែនការគ្រប់គ្រងទាំងអស់មិនត្រូវបានអនុវត្តឲ្យបាន

ពេញលេញ និងពុំត្រូវបានធ្វើបច្ចុប្បន្នភាព។ ប្រទេសកម្ពុជាចាំបាច់ត្រូវបង្កើត ឬបើមានផែនការគ្រប់គ្រងរួចហើយ ត្រូវកែសម្រួល និងអនុវត្តផែនការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ។ ផែនការគ្រប់គ្រងទាំងនេះផ្តល់ការណែនាំសម្រាប់ឈានទៅសម្រេចគោលបំណងក្នុងការរៀបចំឲ្យមានតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។

(ឃ) នៅក្នុងរបាយការណ៍ឆ្នាំ២០១០ ស្តីពីតំបន់ការពារធម្មជាតិដែលបានបញ្ជូនទៅអគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវៈចម្រុះ ប្រទេសកម្ពុជាបានកត់សម្គាល់ថា ខ្លួនពុំមានការរីកចម្រើន ឬពុំទាន់បានចាប់ផ្តើមការងារទាក់ទងនឹងការវាយតម្លៃ និងការកែលម្អនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ (គោលដៅ៤.២ នៃកម្មវិធីការងារស្តីពីតំបន់ការពារធម្មជាតិដែលបានអនុម័តដោយសន្និបាតភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះ)ទេ។គេសង្ឃឹមថាផែនការគ្រប់គ្រងយុទ្ធសាស្ត្រនេះនឹងជំរុញ និងសម្រួលសកម្មភាពទាំងអស់ដែលទាក់ទងនឹងគោលដៅ ៤.២ នៃកម្មវិធីការងារតំបន់ការពារធម្មជាតិរបស់អនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ។ របាយការណ៍បន្ទាប់សម្រាប់អនុសញ្ញាស្តីពីជីវៈចម្រុះនឹងត្រូវបញ្ជូនសម្រាប់កិច្ចប្រជុំលើកក្រោយនៃរដ្ឋភាគីនៅខែតុលា ឆ្នាំ២០១៤។ ដូច្នេះ វាជាការប្រសើរដែលត្រូវរៀបចំផែនការគ្រប់គ្រងយុទ្ធសាស្ត្រឲ្យបានរួចរាល់ និងប្រើប្រាស់ឲ្យបានលឿនបំផុតតាមអាចធ្វើបាន ដើម្បីមានពេលវេលាសម្រាប់អនុវត្ត និងរាយការណ៍ពីការរីកចម្រើននៅក្នុងរបាយការណ៍ជាតិលើកទី៥ ដែលនឹងត្រូវបញ្ជូនទៅកាន់អគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវៈចម្រុះឲ្យបានមុនខែតុលា ឆ្នាំ២០១៥។

(ង) សន្និបាតភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះស្នើឲ្យភាគីទាំងអស់ធ្វើការងារវាយតម្លៃពី ប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិចំនួន៦០% នៃតំបន់ការពារធម្មជាតិសរុបក្នុងប្រទេស មកត្រឹមឆ្នាំ២០១៥[19]។ ផែនការគ្រប់គ្រងយុទ្ធសាស្ត្រនេះគួររៀបចំឲ្យបានរួចរាល់នៅមុនខែនោះដើម្បីឲ្យអាចបង្កើត និង/ឬកែសម្រួល/ធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សសម្រាប់ឲ្យតំបន់ទាំងនេះមានផែនការយ៉ាងតិចចំនួន ៦០ភាគរយ ក្នុងប្រទេសកម្ពុជា។

(ច) ដោយមានការដាក់ពេលកំណត់ សម្រាប់ត្រួតពិនិត្យឡើងវិញនៅត្រឹមឆ្នាំ២០១៥ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាកំណត់ពីគោលបំណង/ចំណុចដៅពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិនិងតំបន់អភិរក្ស។ ចំណុច ដៅទាំងនេះចាំបាច់ត្រូវយកចិត្តទុកដាក់សម្រាប់រៀបចំផែនការគ្រប់គ្រងយុទ្ធសាស្ត្រនិងការអនុវត្តផែនការ ទាំងនេះដោយចាត់ទុកថាជាផ្នែកមួយនៃយុទ្ធសាស្ត្រអនុវត្ត។ របាយការណ៍ស្តីពីលទ្ធផលសម្រេចបាននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ នឹងត្រូវរៀបចំឲ្យបានរួចរាល់នៅឆ្នាំ ២០១៥។

<u>សកម្មភាពសម្រាប់អនុវត្តដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ៖</u>

(ក) កោះប្រជុំដៃគូពាក់ព័ន្ធសំខាន់ៗ (ក្នុងនោះរួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែតំណាងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធនានា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ស្ថាប័នអង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ថ្នាក់តំបន់ ដៃគូពីកិច្ចព្រមព្រៀងទន្លេមេគង្គ និងស្ថាប័នអន្តររដ្ឋាភិបាល តំណាងមកពីអាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន/ផ្នែកជំនួញ)ស្តីពីការរៀបចំផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ រាយការណ៍សង្ខេបជូនតំណាងទាំង

នោះអំពីផែនការរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងស្នើឲ្យពួកគេបញ្ជាក់ពីផ្នែកណាមួយដែលពួកគេអាចចូលរួមបាន។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិអាចត្រូវបានស្នើឱ្យបង្ហាញពីផែនការរបស់ខ្លួនហើយដៃគូផ្សេងៗអាចត្រូវបានអញ្ជើញឲ្យចូលរួច ប្រសិន/នៅពេលចាំបាច់។ កិច្ចប្រជុំដៃគូនេះក៏ត្រូវពិនិត្យសម្រេចលើដំណើរការ និងកម្មវិធីពេលវេលាផងដែរ

(ខ) ធ្វើការវាយតម្លៃឆាប់រហ័សពីប្រសិទ្ធភាពនៃការគ្រប់គ្រង។ អង្គការ WWF និងដៃគូផ្សេងៗទៀតគួរត្រូវបានលើកទឹកចិត្តឲ្យធ្វើការតវាយតម្លៃឆាប់រហ័សដោយផ្អែកលើ RAPPAM ២០០៤

(គ) បន្ទាប់ពីធ្វើការវាយតម្លៃឆាប់រហ័សនៃប្រសិទ្ធភាពគ្រប់គ្រង អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិគួរធ្វើការត្រួតពិនិត្យស៊ីជម្រៅលើការគ្រប់គ្រងបច្ចុប្បន្ននៃតំបន់ការពារធម្មជាតិ និងអភិរក្សក្នុងនោះរួមទាំងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សដែលគ្មានផែនការគ្រប់គ្រងផង។ ការត្រួតនិត្យសកម្មភាពសម្រាប់ការងារសំខាន់ដែលបានកំណត់នៅក្នុងគោលបំណងយុទ្ធសាស្ត្រទី១ និងធ្វើការងារសំខាន់នៅក្នុងគោលបំណងយុទ្ធសាស្ត្រទី២ និងទី៣ ដែលការងារទាំងនេះគឺជាផ្នែកមួយនៃបញ្ជីផ្ទៀងផ្ទាត់សម្រាប់វាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង និងដាក់ចេញអនុសាសន៍សម្រាប់កែលម្អការគ្រប់គ្រង។ សកម្មភាពជាក់លាក់មួយដែលបានកំណត់នៅក្នុងការងារសំខាន់ ២.៣ គឺជាបុរេលក្ខខណ្ឌសម្រាប់ការពិនិត្យស៊ីជម្រៅនេះ ៖ ការកំណត់សញ្ញាបង្ហាញពីព្រំប្រទល់នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងការដាក់សញ្ញាច្បាស់លាស់លើតំបន់គ្រប់គ្រង ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨។ ដូចបានកត់សម្គាល់ក្នុងឧបសម្ព័ន្ធ ៣ ការស្រាវជ្រាវបន្ថែម និងការណែនាំលម្អិតសម្រាប់ការកំណត់តំបន់តម្រូវឲ្យអនុវត្តជាចាំបាច់។

(ឃ) ដោយយកចិត្តទុកដាក់លើការណែនាំដែលមានចែងក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងចក្ខុវិស័យ គោលបំណងយុទ្ធសាស្ត្រ ការងារសំខាន់ៗ សកម្មភាពជាក់លាក់ និងគោលការណ៍ដែលមានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនឹងត្រូវបង្កើតផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ។

(ង) ស្របពេលជាមួយគ្នានេះ អគ្គនាយកដ្ឋាននឹងធ្វើការកែសម្រួល ផ្សព្វផ្សាយ និងប្រើប្រាស់គោលការណ៍ណែនាំបច្ចេកទេសដែលបានបង្កើតឡើងនៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្នុងមាត្រា ៥ និងមាត្រា ១៩ សម្រាប់ដំណើរការស្តង់ដារក្នុងការរៀបចំផែនការសកម្មភាពសម្រាប់តំបន់ការពារធម្មជាតិ និងអភិរក្សនីមួយៗ។ គោលការណ៍ណែនាំបច្ចេកទេសទាំងនេះនឹង (១) បង្កើតឡើងដោយផ្អែកលើបទពិសោធដែលប្រទេសកម្ពុជាទទួលបានពីតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំង៥ដែលមានផែនការគ្រប់គ្រង បើទោះបីជានៅពេលនេះផែនការទាំងនេះមិនទាន់បានធ្វើបច្ចុប្បន្នភាព និងផ្អែកលើផែនការគ្រប់គ្រងសហគមន៍នេសាទ ឬតំបន់នេសាទ (ដែលមានចែងក្នុងច្បាប់ស្តីពីជលផល ឆ្នាំ២០០២) និង(២)ពិនិត្យពិចារណាលើព័ត៌មានលម្អិតអំពីគោលបំណងនៃប្រភេទខុសគ្នារបស់ IUCN ដែលមាននៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងជាការណែនាំយ៉ាងសំខាន់លើប្រភេទនៃវិធីសាស្ត្រគ្រប់គ្រងដែលអាចយកមកប្រើប្រាស់ (មើលឧបសម្ព័ន្ធ១) និង(៣)ស្របនឹងផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ។

(ច) បន្ទាប់ពីការពិនិត្យស៊ីជម្រៅដែលបានលើកឡើងក្នុងផ្នែក (គ) ខាងលើផែនការគ្រប់គ្រងគួរបានរៀបចំឡើង ឬកែសម្រួល/ធ្វើបច្ចុប្បន្នភាពសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗដោយប្រើប្រាស់គោលការណ៍ណែនាំបច្ចេកទេស(មើលចំណុច(ង)ខាងលើ) និងផែនការគ្រប់គ្រងយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ។

### ២. <u>លើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងការពង្រីកនៃប្រព័ន្ធការពារធម្មជាតិ</u>

<u>ចំណុចដៅ ៖</u> (i) ធ្វើការវាយតម្លៃពីការរួមចំណែកដល់ប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មុនឆ្នាំ២០១៥ និងអាចរាយការណ៍នៅក្នុងរបាយការណ៍ថ្នាក់ជាតិលើកទី៥ សម្រាប់អនុសញ្ញាស្តីពីជីវៈចម្រុះ និង (ii) នៅមុនកិច្ចប្រជុំលើកទី១២ នៃសន្និបាតភាគីរបស់អនុសញ្ញាស្តីពីជីវៈចម្រុះ នៅក្នុងខែតុលា ឆ្នាំ២០១៤ ការវិភាគពីកង្វះខាតត្រូវធ្វើឲ្យចប់រួចរាល់ ហើយលទ្ធផលពីការវិភាគនេះត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពជាតិសម្រាប់តំបន់ការពារធម្មជាតិ។

<u>សនិទានភាព ៖</u>

(ក) ចំណុចដៅខាងក្រោមត្រូវបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ត្រឹមឆ្នាំ២០១៥។ លទ្ធផលសម្រេចបាននៃការឈានទៅសម្រេចគោលដៅទាំងនេះចាំបាច់ត្រូវធ្វើការវាយតម្លៃ ហើយការវាយតម្លៃនេះក៏ត្រូវធ្វើ ចំពោះកត្តា/សម្ពាធពាក់ព័ន្ធផ្សេងៗទៀត ៖

(i) ចំណុចដៅ ៧.២ ៖ រក្សានូវផ្ទៃដីតំបន់ការពារធម្មជាតិដែលមានចំនួន ២៣ ក្នុងកម្រិត ៣,៣ លានហិកតា នៅឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១៥

(ii) ចំណុចដៅ ៧.៣ ៖ រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ ក្នុងកម្រិតបច្ចុប្បន្ន ១,៣៥ លានហិកតា ឲ្យនៅថេរដល់ឆ្នាំ ២០១៥

(ខ) លទ្ធផលពីការសិក្សាជាច្រើន ជាពិសេសពីសេដ្ឋកិច្ចនៃគម្រោងគំនិតផ្តួចផ្តើមប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ (TEEB) បង្ហាញថា ចំណេះដឹងជ្រៅជ្រះអំពីតម្លៃសេដ្ឋកិច្ចសង្គម និងមុខងារបរិស្ថាននៃតំបន់ការពារ ធម្មជាតិ និងតំបន់អភិរក្ស ត្រូវការជាចាំបាច់ដើម្បីលើកទឹកចិត្តដល់ការគ្រប់គ្រង និងការរួមចំណែកឲ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលដល់ការអភិវឌ្ឍនប្រកបដោយនិរន្តរភាព។ ទោះជាយ៉ាងនេះក្តី របាយការណ៍ពីប្រទេសកម្ពុជា ឆ្នាំ២០១០[20] ស្តីពីតំបន់ការពារធម្មជាតិបានបញ្ជាក់ថា ការរីកចម្រើនក្នុងការវាយតម្លៃពីការចូលរួមនៃតំបន់ការពារធម្មជាតិដល់សេដ្ឋកិច្ចនៅមូលដ្ឋាន និងថ្នាក់ជាតិ (ដែលនេះគ្រាន់តែជាផ្នែកមួយនៃសេវានានារបស់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស) មានកម្រិតខ្វះខាត ហើយការងារនេះត្រូវបានគេរាយការណ៍ថាទើបតែចាប់ផ្តើមប៉ុណ្ណោះ។

(គ) ប្រទេសកម្ពុជាបានសម្រេចចំណុចដៅចំនួន ១៧ភាគរយនៃចំណុចដៅជីវៈចម្រុះ Aichi ទី ១១ ស្តីពីការគ្របដណ្តប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងលើដី និងក្នុងទឹក។ ការនេះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើលទ្ធផលសម្រេចនេះរួមបញ្ចូលទាំងភាពជាតំណាងផ្នែកអេកូឡូស៊ីដែរឬយ៉ាងណាទេ។ ជាងនេះទៀត ប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើឲ្យសម្រេចលទ្ធផលចំនួន ១០ ភាគរយក្នុងការ

ការពារតំបន់ឆ្នេរសមុទ្រ និងសមុទ្រ និងការចែករំលែកដោយសមធម៌ នៃការចំណាយ និងផលប្រយោជន៍ពីតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។

(ឃ) ចំណុចទី ៨ (ស្មើនឹងចំណុចដៅជីវៈចម្រុះ Aichi ទី១១) គឺត្រូវបន្តការពារ និងអភិរក្សតំបន់ការពារធម្មជាតិ ដែលមានស្រាប់ និងការពារព្រៃប្រព័ន្ធអេកូឡូស៊ីទឹកសាប និងតំបន់ឆ្នេរសមុទ្រ និងសមុទ្របន្ថែមទៀត។

(ង) ប្រទេសកម្ពុជាបានធ្វើការវិភាគពីភាពខ្វះចន្លោះរបស់ខ្លួនរួចហើយ និងជាចាំបាច់ គ្រាន់តែអនុវត្តលទ្ធផលលទ្ធផលនៃការវិភាគដែលទាក់ទងនឹងព្រៃឈើ និងតំបន់ឆ្នេរសមុទ្រ និងសមុទ្រប៉ុណ្ណោះ[21]។

<u>សំណើសកម្មភាពសម្រាប់អនុវត្តដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ៖</u>

(ក) វាយតម្លៃជាទូទៅនូវតំបន់ការពារធម្មជាតិទាំង ២៣ កន្លែង ដោយពិចារណាពីការកំណត់គោលដៅថ្នាក់ជាតិសម្រាប់ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងធ្វើការវាយតម្លៃទូទៅនូវតំបន់ការពារព្រៃដែលបានបង្កើតឡើង រួមទាំងសម្ព័ន្ធនានាទៅលើតំបន់ការពារទាំងនេះ។

(ខ) ផ្តួចផ្តើមដំណើរការបង្កើតតំបន់ការពារធម្មជាតិថ្មីដោយផ្អែកលើអនុសាសន៍ទទួលបានពីការវិភាគភាពខ្វះចន្លោះសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិលម្អិត និងតំណាងអេកូឡូស៊ី។

(គ) ដោយទាញយកប្រយោជន៍ពីការងារ RAPPAM តាមអនុសាសន៍ត្រង់ចំណុច ១(ខ) ខាងលើ នាយកគ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយត្រូវផ្តល់ព័ត៌មានអំពីតម្រូវការ និងសេវាប្រព័ន្ធអេកូឡូស៊ីពីតំបន់ការពារធម្មជាតិ ឬតំបន់អភិរក្ស ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ តម្រូវការដែលបានរកឃើញនឹងត្រូវយកមកប្រើជាមូលដ្ឋានសម្រាប់ប៉ាន់ស្មានពីថវិកាសម្រាប់តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ និងសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ។ ការប៉ាន់ស្មានថវិកាទាំងនេះនឹងត្រូវប្រើប្រាស់សម្រាប់កៀងគរធនធាន (មើលផ្នែក ៣ ខាងក្រោម)។ ការរៀបរាប់ពីផលប្រយោជន៍ផ្ទាល់ និងតម្លៃប្រយោលនៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនឹងត្រូវភ្ជាប់នូវបញ្ជីបង្ហាញពីផលប្រយោជន៍នៃតំបន់ទាំងនោះ (ឧ. កំណើនស្តុកត្រី ទឹកសាប) ការគ្រប់គ្រង (ឧ. ការកាត់បន្ថយគ្រោះធម្មជាតិ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈស្តុកកាបូននៅតាមដើមឈើ/បន្លែ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ) និងសេវាគាំទ្រ (ឧ. កិច្ចអភិរក្សធនធានសេនេទិក ដំណាំដែលបានដាំ ប្រភេទសត្វ/រុក្ខជាតិ និងដែនជម្រកសត្វ/ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងសេវាកំសាន្ត (ឧ. វិស័យទេសចរណ៍) និងតម្លៃសាសនា/វប្បធម៌នៃតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សនីមួយៗ។ បញ្ជីទាំងនេះអាចត្រូវបានយកមកប្រើប្រាស់ជាព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រង និងគោលនយោបាយទាក់ទងនឹងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សក្នុងនោះរួមទាំងសម្រាប់គោលបំណងនៃការកំណត់តំបន់សម្រាប់វិនិយោគ ឬសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ[22]

(ឃ) ស្របតាមមាត្រា ៣១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងមាត្រា ១៩ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវធ្វើកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ និងសហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច អង្គការជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីស្តារ និងលើកកម្ពស់បរិស្ថានក្នុងតំបន់រេចរឹលក្នុងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។ សកម្មភាពទាំងនេះនឹងរួមចំណែកដល់ការអនុវត្តចំណុចដៅជីវៈចម្រុះ Aichi ទី១១ និងចំណុចដៅទី ១១ នៃប្រទេសកម្ពុជា។

<u>៣. សកម្មភាពពាក់ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ</u>

(ក) ដោយធ្វើឲ្យលឿនបំផុតតាមដែលអាចធ្វើបាន ប៉ុន្តែជាចាំបាច់ឲ្យបានមុនខែមេសា ឆ្នាំ២០១៤ បញ្ចូលគោលបំណងយុទ្ធសាស្ត្រនៃក្របខណ្ឌយុទ្ធសាស្ត្រនេះទៅក្នុងយុទ្ធសាស្ត្រជីវៈចម្រុះជាតិ និងផែនការសកម្មភាព (NBSAP) ដែលប្រទេសកម្ពុជាកំពុងពិនិត្យកែសម្រួល ជាការឆ្លើយតបទៅនឹងសេចក្តីសម្រេច CBD COP x/31។ នៅក្នុង កថាខណ្ឌ ក.១(គ) នៃសេចក្តីសម្រេចនេះ ភាគីទាំងអស់ត្រូវបានស្នើឲ្យធ្វើការដាក់បញ្ចូលគោលបំណងទាំងនោះឲ្យបានលឿនបំផុតតាមអាចធ្វើបាន និងមិនឲ្យយឺតជាង ៦ ខែ មុនកិច្ចប្រជុំលើកទី១២ នៃសន្និបាតភាគីនៃអនុសញ្ញាជីវៈចម្រុះដែលស្របតាមគោលបំណងយុទ្ធសាស្ត្រទី ២ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

(ខ) ផ្តល់ព័ត៌ទៅដល់នាយកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សអំពីលក្ខខណ្ឌនៃការធ្វើរបាយការណ៍ ដូចជាតាមរយៈសិក្ខាសាលាមួយថ្ងៃ និងស្នើឲ្យនាយកទាំងនោះបញ្ជូនព័ត៌មានរួមចំណែករបស់ខ្លួនសម្រាប់រៀបចំរបាយការណ៍ជាតិលើកទី ៥ និងផ្ញើជូនអគ្គលេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ ការរួមចំណែកដល់ការបោះពុម្ពលើកទី ៤ នៃទស្សនវិស័យជីវៈចម្រុះសាកល និងរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ២០១៥ ក្នុងចំណោមកិច្ចការផ្សេងៗទៀតដែលស្របតាមគោលបំណងយុទ្ធសាស្ត្រ ទី២ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

(គ) រៀបចំឡើងវិញនូវយន្តការផ្សព្វផ្សាយព័ត៌មានជាតិសម្រាប់សម្រួលចាត់ចែងទិន្នន័យ និងការប្រើប្រាស់របស់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសរួមទាំងនាយកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ និងដៃគូរបស់គេដែលស្របតាមគោលបំណងយុទ្ធសាស្ត្រទី ១ (សកម្មភាព ១.២) នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

(ឃ) ធ្វើការប៉ាន់ស្មានថវិកាសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាដោយផ្អែកលើតម្រូវការដែលបានលើកឡើងដោយនាយកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនឹងស្នើដល់គម្រោងគំនិតផ្តួចផ្តើម LifeWeb (តាមរយៈអគ្គលេខាធិការដ្ឋាននៃអនុសញ្ញាជីវៈចម្រុះ) ឲ្យកោះប្រជុំនៃអ្នកផ្តល់ជំនួយសំខាន់ៗ ដែលជាជំហានដំបូងនៅក្នុងយុទ្ធសាស្ត្រជាតិរបស់ខ្លួនក្នុងការកៀរគរធនធានសម្រាប់ប្រព័ន្ធការពារធម្មជាតិ ដោយយកចិត្តទុកដាក់លើតម្រូវការក្នុងការបំពេញមូលនិធិសម្រាប់តំបន់ការពារធម្មជាតិ និងមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិដែលបានកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងច្បាប់ស្តីពីឈើជាតិ ឆ្នាំ ២០០២

(ង) បន្ទាប់ពីការពិគ្រោះយោបល់ជាមួយនឹងក្រសួងផ្សេងៗទៀត គណៈកម្មាធិការអន្តរក្រសួងសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិអាចត្រូវបានបង្កើតឡើង ដោយផ្អែកលើគំរូនៃក្រុមការងារដែលបង្កើតឡើងដោយក្រសួងបរិស្ថាន នៅឆ្នាំ២០០៥ សម្រាប់ការពារតំបន់អេកូឡូស៊ីព្រៃឈើតាមទន្លេមេគង្គក្រោមដោយមានតំណាងមកពីក្រសួងចំនួន ៤ (ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងទេសចរណ៍)។ គណៈកម្មាធិការអន្តរក្រសួងនេះត្រូវជានាំឲ្យមានការពង្រឹង ភាពរលូន និងកម្លាំងក្នុងចំណោមភាគីទាំងអស់ដែលពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស និងបង្កើនការរួមចំណែកដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដែលស្របតាមចក្ខុវិស័យ និងគោលបំណងយុទ្ធសាស្ត្រទី ២ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ

(ច) កិច្ចពិគ្រោះមតិយោបល់ក៏នឹងជានាំឲ្យមានការឯកភាពគ្នាលើគោលនយោបាយ និងផែនការក្នុងចំណោមក្រសួង ផ្នែក និងទីភ្នាក់ងារ បង្កើនកិច្ចសហការ និងភាពរលូនថ្នាក់ជាតិ កម្លាំងសហប្រតិបត្តិការ និងការគ្រប់គ្រងថ្នាក់ជាតិក្នុងចំណោមភាគីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សទាំងអស់ ដែលការនេះនាំឲ្យមានការអនុវត្តប្រព័ន្ធលម្អិតមួយ ការផ្តល់មូលនិធិ និងការធ្វើរបាយការណ៍ បង្កើនការរួមចំណែកដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងចៀសវាងវិធីសាស្ត្រដាច់ដោយដុំក្នុងការការពារ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិរបស់ជាតិសម្រាប់សុខុមាលភាពនៃប្រជាជនកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ននិងអនាគត។

**ឧបសម្ព័ន្ធ៥៖**

## វិធីសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតដែលកំពុងអនុវត្តក្នុងប្រទេសកម្ពុជា

(ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ និងច្បាប់ស្តីពីជលផល ឆ្នាំ២០០៦)

១. ប្រភេទនៃការគ្រប់គ្រងដែលត្រូវបានប្រើសម្រាប់តំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សត្រូវបានកំណត់ក្នុងពេលដែលតំបន់ទាំងនេះត្រូវបានកំណត់ជាតំបន់ការពារធម្មជាតិ ហើយគោលបំណងនៃតំបន់ទាំងនោះក៏បានបញ្ជាក់ផងដែរ

(២) នៅក្នុងប្រទេសកម្ពុជា និងដូចមានការកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ តំបន់ការពារធម្មជាតិទាំងនេះត្រូវបានបែងចែកទៅតាមប្រភេទក្នុងការគ្រប់គ្រងរបស់អង្គការ IUCN ៖

- (ក) ឧទ្យានជាតិ (ប្រភេទ IUCN ទី២)
- (ខ) ដែនជម្រកសត្វព្រៃ (ប្រភេទ IUCN ទី៤)
- (គ) តំបន់ការពារទេសភាព (ប្រភេទ IUCN ទី៥)
- (ឃ) តំបន់ប្រើប្រាស់ច្រើនយ៉ាង (ប្រភេទ IUCN ទី៦)

(៣) តំបន់ការពារធម្មជាតិមួយចំនួនត្រូវបានកំណត់ថាជាតំបន់ (១)តំបន់រ៉ាមសារ (២)តំបន់បឋមនីយជីវមណ្ឌល (៣)តំបន់បេតិកភណ្ឌធម្មជាតិ (៤)ឧទ្យានជាតិសមុទ្រ ឬ(៥)សហគមន៍តំបន់ការពារធម្មជាតិ

(៤) គោលបំណង/សកម្មភាពដែលត្រូវអនុវត្ត នៅក្នុងតំបន់ការពារនីមួយៗនៃតំបន់ការពារធម្មជាតិមាននៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការការពារធម្មជាតិ ឆ្នាំ២០០៨ និងត្រូវបានដាក់រៀបចំឡើងវិញនៅក្នុងតារាង១

(៥) ជំហានខាងក្រោមនេះគឺជាការបែងចែកនៃតំបន់ការពារឲ្យទៅជាតំបន់គ្រប់គ្រង។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ បញ្ជាក់ពីប្រភេទតំបន់ចំនួនបួន ដូចមានរៀបរាប់នៅក្នុងតារាង ២។ តំបន់នីមួយៗចាំបាច់ត្រូវការវិធីសាស្ត្រដាក់លាក់ក្នុងការគ្រប់គ្រង។ទោះជាយ៉ាងនេះក្តីវិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ី (http://www.cbd.int/ecosystem/) ឬវិធីសាស្ត្រពាក់ព័ន្ធផ្សេងៗទៀតគួរត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ជាវិធីគ្រប់គ្រងតំបន់នីមួយៗ ហើយការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃតំបន់ទាំងនេះក៏គួរបានអនុវត្តតាមគោលការណ៍ Addis Ababa និងគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ជីវៈចម្រុះប្រកបដោយនិរន្តរភាព (http://www.cbd.int/sustainable/addis.shtml) ។ ក្រៅពីនេះការកំណត់តំបន់គួរយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុផងដែរ។ ការសាងសង់ ឬការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគួរទទួលបានការគាំទ្រពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដោយពិនិត្យជាពិសេសទៅលើជីវៈចម្រុះ។

(៦) វិធីសាស្ត្រគ្រប់គ្រងដែលត្រូវការសម្រាប់តំបន់ពិសេសមួយនឹងអាស្រ័យជាពិសេសលើអេកូឡូស៊ី (លក្ខណៈរូបសាស្ត្រ-គីមី និងជីវៈសាស្ត្រ)នៃតំបន់នោះ រួមទាំងសេវាប្រព័ន្ធអេកូឡូស៊ីនៃតំបន់នោះ តម្លៃតំបន់ការពារធម្មជាតិ ទៅតាមការយល់ឃើញរបស់អ្នកប្រើប្រាស់ និងការគំរាមកំហែង ព័ត៌មានមូលដ្ឋាន និងបទដ្ឋាន។ វិធីសាស្ត្រដែលត្រូវយកទៅប្រើប្រាស់នោះ នឹងត្រូវពឹងផ្អែកលើសមត្ថភាពដែលមានស្រាប់(ជាពិសេសសមត្ថភាពមនុស្ស សមត្ថភាពបច្ចេកទេស និងសមត្ថភាពហិរញ្ញវត្ថុ)

(៧) វិធីសាស្ត្រទាំងនេះត្រូវបានដាក់តាមក្រុមដូចខាងក្រោម ៖

(ក) ការអភិរក្ស ក្នុងនោះរួមទាំងការកសាង និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធ

(ខ) ការស្តារ និងការកាត់បន្ថយនៃផលប៉ះពាល់អវិជ្ជមាន

(គ) ការប្រើប្រាស់ប្រកបដោយនិរន្តរភាព

(ឃ) ការត្រួតពិនិត្យ និងការបង្ក្រាបសកម្មភាពខុសច្បាប់

(ង) ការទប់ស្កាត់

(ច) វិធីសាស្ត្រដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ

(៨) វិធីសាស្ត្រមួយចំនួនក្នុងចំណោមវិធីសាស្ត្រទាំងនេះក៏ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨។ កញ្ចប់ព័ត៌មានត្រូវបានបង្កើតឡើងសម្រាប់វិធីសាស្ត្រនីមួយក្នុងចំណោមវិធីសាស្ត្រទាំងនេះ ឧ. មើលពីទំព័រ ៤១ ដល់ទំព័រ ៤៣ នៃឯកសារបច្ចេកទេសលេខ ១៨ នៃអនុសញ្ញាស្តីពីជីវៈចម្រុះ ព័ត៌មាន មាននៅ http://www.cbd.int/protected/ under tools and e-learning modules។

(៩) ក្នុងអំឡុងពេលនៃការអនុវត្តផែនការគ្រប់គ្រង អ្នកអនុវត្តអាចប្រឈមនឹងឧបសគ្គនានា ដូចជា ភ្លើងឆេះព្រៃ ការរុករករ៉ែ គ្រោះរាំងស្ងួត ការចូលលុកលុយនៃប្រភេទសត្វ/រុក្ខជាតិពីខាងក្រៅ។ ការគ្រប់គ្រងចាំបាច់ត្រូវកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង។

តារាង ១ ៖ គោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ

| ការកំណត់តំបន់ការពារធម្មជាតិ | គោលបំណង/សកម្មភាព |
|---|---|
| **ឧទ្យានជាតិ ៖** តំបន់ធម្មជាតិក្នុងដែនដីគោក និង/ឬដែនទឹកដែលត្រូវបានបង្កើតឡើងដើម្បី ៖<br>ក. ការពារតួនាទីមួយ ឬច្រើននៃតំបន់នេះក្នុងប្រព័ន្ធអេកូឡូស៊ីសម្រាប់ផលប្រយោជន៍របស់មនុស្សគ្រប់ជំនាន់។<br>ខ. រឹតត្បិតការប្រើប្រាស់ដែលអាចប៉ះពាល់ ឬបំផ្លិចបំផ្លាញធនធានជីវៈ ធនធានធម្មជាតិ ធនធានវប្បធម៌ និងតួនាទី/មុខងារនៃតំបន់នេះពាក់ព័ន្ធនឹងគោលបំណងក្នុងការបង្កើតតំបន់នោះ<br>គ. ជាកន្លែងសម្រាប់កំសាន្ត ដំណើរទេស្សនៈកិច្ច ការអប់រំ ការស្រាវជ្រាវ និងជំនឿ ប្រសិនបើសកម្មភាពទាំងនេះមិនបង្កការគំរាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌មូលដ្ឋាន | ១. ការពារតំបន់ធម្មជាតិ និងតំបន់ទេសភាពដែលមានសារៈសំខាន់ជាតិ និងអន្តរជាតិសម្រាប់ជំនឿ វិទ្យាសាស្ត្រ ការអប់រំ ការកំសាន្ត និងទេសចរណ៍<br>២. រក្សាកត្តាជាអាទិភាពសម្រាប់សំណាករូបសាស្ត្រ-ភូមិសាស្ត្រសម្រាប់តំបន់ សហគមន៍ធនធានមានជីវិត ធនធានសេនេទិក និងប្រភេទរុក្ខជាតិ/សត្វដើម្បីឲ្យមានស្ថិរភាព និងភាពចម្រុះនៃអេកូឡូស៊ី<br>៣. គ្រប់គ្រងការប្រើប្រាស់របស់ភ្ញៀវទេសចរសម្រាប់គោលដៅជំនឿ ការអប់រំ វប្បធម៌ និងការកំសាន្ត ក្នុងកម្រិតមួយដែលមិនរំខិត ឬមានការរំខានតិចតួចដល់តំបន់<br>៤. លុបបំបាត់ និងទប់ស្កាត់ការប្រើប្រាស់ និងការកាន់កាប់ផ្នែកណាមួយនៃតំបន់នេះដោយខុសច្បាប់<br>៥. បន្តការគោរពគុណសម្បត្តិអេកូឡូស៊ី ទម្រង់ដី ភាពពិសិទ្ធ ឬសោភ័ណភាពដែលជាបុព្វហេតុចម្បងក្នុងការបង្កើតតំបន់ការពារធម្មជាតិ<br>៦. ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមជនជាតិដើមភាគតិច ក្នុងនោះរួមទាំងការប្រើប្រាស់ធនធានជម្រើស ក្នុងកម្រិតមួយដែលអាចឈានទៅសម្រេចគោលបំណងនៃការគ្រប់គ្រង |
| **ដែនជម្រកសត្វព្រៃ ៖** តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលតម្រូវឲ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់គោលបំណងគ្រប់គ្រង ដើម្បីធានាឲ្យមានការថែទាំទីជម្រក និង/ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ ឬរុក្ខជាតិ។ | ១. ការពារ និងថែរក្សាលក្ខខណ្ឌនៃទីជម្រកចាំបាច់សម្រាប់ប្រភេទសត្វ/រុក្ខជាតិមានជីវិត ជាពិសេសសត្វព្រៃយ៉ាងសំខាន់ដែលតម្រូវឲ្យមានអន្តរាគមន៍គ្រប់គ្រង។<br>២. ជាកន្លែងសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការអង្កេតបរិស្ថានដើម្បីគ្រប់គ្រងធនធានធម្មជាតិឲ្យមានប្រសិទ្ធភាពទាំងនៅក្នុង និងនៅក្រៅតំបន់នោះ<br>៣. ជាកន្លែងសម្រាប់ការអប់រំសាធារណៈ និងការស្វែងយល់អំពីការទំនាក់ទំនងគ្នាទៅវិញទៅមកនៃជម្រកសត្វពាក់ព័ន្ធ និងការគ្រប់គ្រងសត្វព្រៃ<br>៤. លុបបំបាត់ និងទប់ស្កាត់ការប្រើប្រាស់ និងការកាប់ផ្នែកណាមួយនៃតំបន់នេះដោយខុសច្បាប់<br>៥. ផ្តល់ឲ្យប្រជាជន ជាពិសេសសហគមន៍មូលដ្ឋានដែលកំពុងរស់នៅក្នុង |

| | |
|---|---|
| | ដែនជម្រកសត្វព្រៃនូវផលប្រយោជន៍ក្នុងកម្រិតមួយដែលសមស្រប ទៅនឹងគោលបំណងគ្រប់គ្រងផ្សេងៗទៀត |
| **តំបន់ការពារទេសភាព ៖** តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលតំបន់ទាំងនេះទទួលរងនូវអន្តរអំពើរបស់មនុស្សទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ដែលមានលក្ខណៈប្លែកខាងផ្នែកសោភ័ណភាពធម្មជាតិ ឬកែច្នៃអេកូឡូស៊ី ឬវប្បធម៌ និងជាទូទៅសម្បូណ៌ដោយជីវៈចម្រុះ។ ការថែរក្សាអន្តរអំពើជាប្រពៃណីបែបនេះមានមានសារៈសំខាន់ជាអាយុជីវិតចំពោះកិច្ចការពារ ថែរក្សា និងការវិវឌ្ឍតំបន់បែបនេះ។ | ១. រក្សាអន្តរកម្មទៅវិញទៅមកនៃកត្តាធម្មជាតិ និងវប្បធម៌តាមរយៈការការពារតំបន់ទេសភាពធម្មជាតិក្នុងដែនគោក ឬតំបន់ទេសភាពធម្មជាតិឆ្នេរសមុទ្រ ឬដែនគោក ឬទាំងពីរ និងរក្សាទម្រង់ជាប្រពៃណីនៃការប្រើប្រាស់ដី ទម្រង់នៃការសាងសង់ និងមុខងារតាមរយៈសកម្មភាពសង្គម និងវប្បធម៌<br>២. គាំទ្រដល់សកម្មភាពជីវិតរស់នៅ និងសេដ្ឋកិច្ចជាប្រពៃណីដែលមានទំនាក់ទំនងសមស្របជាមួយនឹងធម្មជាតិ និងរក្សាទំនាក់ទំនងរវាងសកម្មភាពសង្គម និងវប្បធម៌របស់សហគមន៍ពាក់ព័ន្ធ<br>៣. បន្តថែរក្សាទម្រង់ខុសៗគ្នានៃទេសភាព និងទីជម្រក ព្រមទាំងប្រភេទសត្វ/រុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ី<br>៤. លុបបំបាត់ និងទប់ស្កាត់ការប្រើប្រាស់ដី និងសកម្មភាពដែលសមស្របទាំងទហំ ឬទម្រង់ ឬទាំងពីរប្រភេទ<br>៥. ផ្តល់ឱកាសដល់ការរីករាយដល់សាធារណជន តាមរយៈការកំសាន្ត និងសកម្មភាពទេសចរណ៍ ដែលមានលក្ខណៈសមស្របគុណភាពយ៉ាងសំខាន់នៃតំបន់ ទាំងទំហំ និងទម្រង់<br>៦. លើកទឹកចិត្តដល់ការស្រាវជ្រាវ និងសកម្មភាពអប់រំដែលរួមចំណែករយៈពេលយូរអង្វែងដល់ការគាំទ្រសុខុមាលភាពមនុស្សក្នុងតំបន់ និងការគាំទ្រសាធារណជនជាលក្ខណៈចល័តសម្រាប់ការការពារបរិស្ថានតំបន់<br>៧. ផ្តល់ប្រយោជន៍ និងរួមចំណែកដល់ការគាំទ្រសុខុមាលភាពនៃសហគមន៍មូលដ្ឋានតាមរយៈការផ្តល់ផលិតផល និងសេវាធម្មជាតិ |
| **តំបន់ប្រើប្រាស់ច្រើនយ៉ាង ៖** តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលក្នុងនោះមានសម្បូណ៌ដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងដែលតម្រូវឲ្យមានសកម្មភាពគ្រប់គ្រងដើម្បីធានាការការពារ និងការថែទាំធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីសម្រាប់ | ១. ការពារ និងថែរក្សាជីវៈចម្រុះ និងតម្លៃធម្មជាតិនៃតំបន់រយៈពេលយូរអង្វែង<br>២. លើកកម្ពស់ការគ្រប់គ្រងដើម្បីឈានទៅសម្រេចគោលដៅក្នុងការ ផលិតផលិតផលប្រកបដោយនិរន្តរភាព<br>៣. ការពារមូលដ្ឋាននៃធនធានធម្មជាតិដើម្បីទប់ស្កាត់ការកែប្រែដីនៃការប្រើប្រាស់ដីដែលបង្កគ្រោះគំរាមកំហែងដល់ជីវៈចម្រុះក្នុងតំបន់នោះ<br>៤. រួមចំណែកដល់សេដ្ឋកិច្ច និងការអភិវឌ្ឍមូលដ្ឋាន និងជាតិ |

| | |
|---|---|
| ពេលយូរអង្វែង។ ទន្ទឹមនឹងនោះដែរ អាចផ្តល់ផលិតផល និងសេវាធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។ | |
| **តំបន់រ៉ាមសារ ៖** តំបន់ដីសើមដែលគេចាត់ទុកថាជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ | ការពារធនធានដីសើមដែលមានចំណាប់អារម្មណ៍ជាអន្តរជាតិ និងមានសារៈសំខាន់អេកូឡូស៊ី ឬជីវៈ ជាពិសេសសម្រាប់ជម្រកបក្សីទឹកដែលរងការគម្រាមកំហែង និងមានចំនួនធ្លាក់ចុះយ៉ាងកំហុក និងជាជម្រកសម្រាប់បក្សីទឹកដែលមានការបំលាស់ទី។ |
| **តំបន់បបនីយជីវមណ្ឌល** ទន្លេសាប ៖ តំបន់បបនីយជីវមណ្ឌលជាតំបន់តំណាងឲ្យប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់ និងពុំរងនូវការខូចខាត ខ្លាំងហើយព័ទ្ធជុំវិញទៅដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាពដែលអនុញ្ញាតិឲ្យមានសកម្មភាពមនុស្សក្នុងកម្រិតមួយកំណត់។ | តំបន់បបនីយជីវមណ្ឌលទន្លេសាប ត្រូវបានបង្កើតឡើង ដើម្បី ៖<br>១. អភិរក្សជីវៈចម្រុះ ទេសភាព ទម្រង់ដី និងប្រព័ន្ធអេកូឡូស៊ី ក្នុងនោះរួមទាំងធនធានសេនេទិក រុក្ខជាតិ មច្ឆាជាតិ និងសត្វ និងស្ថានបរិស្ថាន និងទីជម្រកជីវៈ<br>២. គាំទ្រដល់ការអភិវឌ្ឍអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌<br>៣. គាំទ្រដល់សកម្មភាព រួមទាំងការអនុវត្តគម្រោងសាកល្បង ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងស្ទង់មតិដើម្បីពិនិត្យការប្រែប្រួលបរិស្ថាន នៅថ្នាក់មូលដ្ឋាន ជាតិ និងអន្តរជាតិ |
| **តំបន់បេតិកភណ្ឌធម្មជាតិ ៖** តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិ ឬពាក់កណ្តាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោ ឬប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រ មានគុណភាពជាតំណាងឲ្យប្រព័ន្ធធម្មជាតិនានា ឬមានគុណភាពខាងផ្នែកសោភ័ណភាព ឬសារៈសំខាន់ផ្នែកវប្បធម៌។ | ១. ការពារ និងថែរក្សានិរន្តរភាពនៃលក្ខណៈធម្មជាតិដោយសារតែសារៈសំខាន់ធម្មជាតិពិសេសនៃតំបន់នោះ មានលក្ខខណៈប្លែកពីគេ និងតំណាងនៃប្រព័ន្ធអេកូឡូស៊ី និងសារៈសំខាន់សម្រាប់ជំនួយដល់ចិត្តសាស្ត្រ ឬសារៈសំខាន់ដោយសារតែការរួមផ្សំគ្នានៃកត្តាទាំងនោះ<br>២. ផ្តល់ឱកាសឲ្យមានការស្រាវជ្រាវ ការអប់រំ ការពន្យល់អំពីធម្មជាតិ និងការចូលរួមពីសាធារណជនក្នុងកម្រិតមួយដែលធានាឲ្យមានភាពសមស្របតាមចំណុចទី១ ខាងលើ<br>៣. លុបបំបាត់ និងទប់ស្កាត់ការប្រើប្រាស់ និងការកាន់កាប់ដែលមិនស្របនឹង ឬបង្កឲ្យមានផលប៉ះពាល់ដល់គោលបំណងនៃការបង្កើតតំបន់ការពារធម្មជាតិ<br>៤. ផ្តល់ឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិកភណ្ឌធម្មជាតិ (បើមាន) នូវផលប្រយោជន៍ ក្នុងកម្រិតមួយស្របទៅនឹងគោល បំណងនៃការគ្រប់គ្រង |
| **ឧទ្យានជាតិសមុទ្ទ ៖** តំបន់ឆ្នេរសមុទ្រ | ១. ថែរក្សា និងការពារធនធានជីវៈចម្រុះសមុទ្រ និងមុខងារព្រៃឈើ |

| | |
|---|---|
| ទទួលឥទ្ធិពលជំនោរសមុទ្រលាយឡំជាមួយនឹងទឹកពីព្រែកភ្នំ រួមទាំងកោះគ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆាជាតិគ្រប់ប្រភេទ មានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ហើយតំបន់នេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងគ្រប់គ្រងឲ្យមានប្រសិទ្ធភាព | ២. ថែរក្សា និងការពារគុណភាពបរិស្ថានសមុទ្រសម្រាប់រយៈពេលយូរអង្វែង<br>៣. ថែទាំ និងការពារតំបន់ប្រវត្តិសាស្ត្រ និងតម្លៃពិសេសខាងវប្បធម៌ និងធម្មជាតិសមុទ្រ<br>៤. ផ្តល់ឱកាសឲ្យមានការស្រាវជ្រាវវិទ្យាសាស្ត្រ ការអប់រំ ការកំសាន្ត និងទេសចរសមុទ្រ |

តារាង ២ ៖ ប្រព័ន្ធគ្រប់គ្រងតំបន់ទាំង ៤ ដែលមានចែងក្នុងជំពូក ៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨

| ប្រភេទតំបន់ | លក្ខណៈតំបន់ |
|---|---|
| តំបន់ស្នូល | តំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលមានកម្រិតជិតផុតពូជខ្ពស់ ទទួលរងគ្រោះថ្នាក់ គំរាមកំហែងនិងមានប្រព័ន្ធអេកូស៊ីផុយស្រួយ។ ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។ |
| តំបន់អភិរក្ស | តំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ការចេញ ចូលតំបន់នេះត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះសម្រាប់ជីវភាពសហគមន៍ជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ |
| តំបន់ប្រើប្រាស់ដោយចិរភាព | តំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។ |
| តំបន់សហគមន៍ | តំបន់គ្រប់គ្រងបម្រើឲ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិចដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចម្ការ។ |

## ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

១. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ កំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើក្នុងប្រទេសកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌។

២. នៅចំណុចចាប់ផ្តើម ក្នុងមាត្រា ៣ ច្បាប់នេះបញ្ជាក់ថា ការគ្រប់គ្រងតំបន់ការពារធម្មជាតិស្ថិតនៅក្រោមក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិនានាដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថានឆ្នាំ១៩៩៦ និងព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ឆ្នាំ១៩៩៣។ នៅក្នុងមាត្រាដដែលនេះ ច្បាប់នេះទទួលស្គាល់ថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយជាមួយក្រសួងបរិស្ថាន។

៣. នៅក្នុងមាត្រា ៨ នៃជំពូក ៣ ច្បាប់នេះចែងពីចំណុចពាក់ព័ន្ធនានាដូចខាងក្រោម ៖

(ក) ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ

(ខ) ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិដោយមានការចូលរួមយ៉ាងទូលំទូលាយពីអាជ្ញាធរ និងសហគមន៍ពាក់ព័ន្ធ

(គ) ផែនការគ្រប់គ្រងព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ប្រាំ (៥) ឆ្នាំម្តង ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ។ ប្រធានបទដែលត្រូវលើកមកបញ្ជាក់នៅក្នុងផែនការគ្រប់គ្រងព្រៃឈើជាតិមានបញ្ជាក់នៅក្នុងមាត្រា៨ នៃច្បាប់នេះ។

៤. ច្បាប់នេះប្រើប្រាស់បច្ចេកស័ព្ទនានាដូចខាងក្រោម សំដៅដល់តំបន់ព្រៃឈើសម្រាប់ការពារ ឬអភិរក្ស ៖

(ក) ព្រៃបម្រុងទុកអចិន្ត្រៃយ៍ រួមទាំងព្រៃផ្តល់ផល និងព្រៃការពារ។ បច្ចេកទេសទាំងអស់នេះមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ/សន្ទានុក្រម។

(១) ព្រៃការពារគឺជាតំបន់ព្រៃដែលមានមុខងារចំបងសម្រាប់ការពារប្រព័ន្ធមជ្ឈដ្ឋានជាអាទិ៍និយតភាពធនធានទឹក អភិរក្សជីវៈចម្រុះ អភិរក្សដី ទីជម្រាល តំបន់រងទឹកភ្លៀង ជម្រកសត្វព្រៃមច្ឆជាតិ រាំងទឹកជំនន់ រាំងការហូរច្រោះ រាំងការទន្រានទឹកសមុទ្រ រក្សាដីជាតិដី ឬមានតម្លៃសម្រាប់សម្បត្តិវប្បធម៌ដែលបម្រើប្រយោជន៍សាធារណៈ។ ព្រៃការពារមិនបញ្ចូលនូវតំបន់ការពារធម្មជាតិ ក្រោមយុត្តាធិការនៃក្រសួងបរិស្ថានឡើយ។

(២) ព្រៃផ្តល់ផលគឺជាព្រៃដែលរក្សាទុកដែលមានមុខងារចម្បងសម្រាប់ផលិតកម្មផលព្រៃឈើ និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព។មុខងារការពារត្រូវបានចាត់ទុកជាមុខងារសំខាន់ទីពីរ។ ព្រៃទាំងនេះរួមទាំងព្រៃសហគមន៍ផង។

(ខ) ព្រៃសហគមន៍គឺជាព្រៃរដ្ឋដែលបានផ្តល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខ័ណ្ឌរដ្ឋបាលព្រៃឈើជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬក្បែរព្រៃដែលពឹងផ្អែកលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី។

(គ) ព្រៃការពារដូចបានរៀបរាប់ក្នុងឧបសម្ព័ន្ធគឺជាដីព្រៃឈើរដ្ឋដោយគ្របដណ្តប់ជាសំខាន់ដោយព្រៃកម្រិតទីពីរ និងមិនទាន់បានកំណត់សម្រាប់ការប្រើប្រាស់ដែលត្រូវបានដាក់ជាបណ្តោះអាសន្នក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍។

(ឃ) ក្រមគ្រប់គ្រងព្រៃឈើកម្ពុជាសំដៅដល់គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្ត ប្រកបដោយនិរន្តរភាពក្នុងការគ្រប់គ្រងព្រៃឈើក្នុងប្រទេសកម្ពុជា (កម្មវិធីព្រៃឈើជាតិកម្ពុជា ឆ្នាំ ២០០៨)។ គោលការណ៍ណែនាំទាំងនេះមានដូចជា ៖

- (ក) ក្រមប្រតិបត្តិកម្ពុជាសម្រាប់ការប្រមូលផលព្រៃឈើ
- (ខ) គោលការណ៍ណែនាំសម្រាប់ប្រព័ន្ធរៀបចំផែនការគ្រប់គ្រងសម្បទានព្រៃ
- (គ) គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងតំបន់ពិសេស
- (ឃ) គោលការណ៍ណែនាំអភិរក្សជីវៈចម្រុះសម្រាប់ព្រៃគ្រប់គ្រង
- (ង) គោលការណ៍ណែនាំសម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមក្នុងសហគមន៍នៅជុំវិញតំបន់សម្បទានព្រៃ
- (ច) គោលការណ៍សម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់សម្បទានព្រៃ
- (ឆ) គោលការណ៍ណែនាំសម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់សម្បទានព្រៃការពារ

**ច្បាប់ស្ដីពីជលផល ឆ្នាំ២០០៦**

១. គោលបំណងសំខាន់នៃច្បាប់ស្ដីពីជលផល ឆ្នាំ២០០៦ គឺដើម្បីធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍវារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះផងទាំងមរតកវប្បធម៌ធម្មជាតិផងប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា(មាត្រ១)

២. មាត្រា៣ នៃច្បាប់នេះចែងថា ការគ្រប់គ្រងជលផល ដោយរួមទាំងព្រៃលិចទឹក និងព្រៃកោងកាងត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទោះជាយ៉ាងនេះក្ដី ក្រសួងបរិស្ថានត្រូវមានសិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្ដីពីកិច្ចការបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាព ពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសជលផលដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ដោយធ្វើការធានាថា សកម្មភាពទាំងនេះនឹងមិនធ្វើឲ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្ដីពីកិច្ចការពារ និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

៣. ច្បាប់នេះប្រើប្រាស់បច្ចេកស័ព្ទមួយចំនួនដូចខាងក្រោមសម្រាប់ការការពារ និងអភិរក្សតំបន់ទឹកប្រៃ និងតំបន់ទឹកសាប ៖

(ក) តំបន់អភិរក្សធនធានជលផល (មាត្រា ៨) តំណាងឲ្យកម្រិតនៃការគ្រប់គ្រងជលផលដែលក្នុងនោះរួមមាន តំបន់ទឹកហូរនិងរណ្ដៅជ្រៅៗនៅតាមទន្លេនានា ទន្លេសាប ទន្លេ ព្រៃលិចទឹក ប្រជុំកោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាងដែលមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល។

(ខ) តំបន់រងទឹកជំនន់ការពារ (នៅក្នុងសន្ទានុក្រម) និងតំបន់ព្រៃលិចទឹកការពារ (មានកំណត់នៅក្នុងមាត្រា ១០)

(គ) "តំបន់អភិរក្សជលផល" (ដែនសមុទ្ទ និងដែនទឹកសាប) ដែលជាជម្រករុក្ខជាតិ និងសត្វក្នុងទឹក (មាត្រា ១០) សំដៅដល់ការចាត់ចំណាត់ថ្នាក់នៃដែនទឹកសាប ឬដែនទឹកប្រៃ ដោយមានការកំណត់ពីព្រំប្រទល់ភូមិសាស្ត្រយ៉ាងច្បាស់លាស់សម្រាប់វារីសត្វ និងវារីរុក្ខជាតិ ដើម្បីរស់នៅ ពងកូន ស្វែងរកចំណី និងរីកធំធាត់។ តំបន់អភិរក្សជលផលគឺជាតំបន់ពងកូន និងតំបន់ការពារជលផល ក្នុងសកម្មភាពដែលនាំឲ្យប៉ះពាល់អវិជ្ជមានលំធនធានជលផលត្រូវហាមឃាត់ជាដាច់ខាតលើកលែងតែ តែធ្វើឡើងក្នុងគោលបំណងស្រាវជ្រាវវិជ្ជាសាស្ត្រដែលមានការអនុញ្ញាត ដោយមានគោលការណ៍សមស្រប (ក្នុងឧបសម្ព័ន្ធ)។

(ឃ) ជម្រកមច្ឆជាតិ ត្រូវថែរក្សា និងការពារ (មាត្រា ២៦)

(ង) តំបន់ព្រៃការពារ (មើល "តំបន់ព្រៃអភិរក្ស" ខាងលើ)

(ច) កន្លែងនេសាទសហគមន៍ (មាននៅក្នុងឧបសម្ព័ន្ធផងដែរ) គឺជាដែននេសាទរបស់រដ្ឋដែលបានប្រគល់ឲ្យសហគមន៍នេសាទក្រោមកិច្ចព្រៀមព្រៀងរវាងប្រធានខណ្ឌជលផលនៃរដ្ឋបាលជលផល និងសហគមន៍ ឬក្រុមមនុស្សរស់នៅក្នុង ឬជុំវិញដែននេសាទនោះ។ ប្រជាជនទាំងនេះពឹងផ្អែកជាសំខាន់លើជលផលសម្រាប់ជីវិតរស់នៅ និងប្រើប្រាស់ឧបករណ៍នេសាទជាប្រពៃណីដោយពួកគេគ្រប់គ្រង និងប្រើប្រាស់តំបន់ទាំងនោះដោយនិរន្តរភាព។ ដូចមានចែងក្នុងមាត្រា ៦២ កន្លែងនេសាទសហគមន៍ត្រូវតែស្ថិតក្រោមការគ្រប់គ្រងជាប្រចាំរបស់សហគមន៍នេសាទស្របតាមផែនការគ្រប់គ្រងសហគមន៍នេសាទ/ជលផល នីតិវិធី និងគោលការណ៍ណែនាំរបស់សហគមន៍នេសាទ។ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដោយសហគមន៍មូលដ្ឋាន និងទទួលបានការឯកភាពពីប្រធាន នៃរដ្ឋបាលជលផលថ្នាក់ជាតិ និងត្រូវធ្វើការត្រួតពិនិត្យឡើងវិញនៅរៀងរាល់ ៣ ឆ្នាំម្តង ឬមុនពេលកំណត់នេះ នៅពេលចាំបាច់។

**ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧**

១. ច្បាប់នេះ មានគោលបំណងជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តភាពតាមរយៈការកំណត់ សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក (មាត្រាទី១) ចំណែកឯមាត្រាទី៤ នៃច្បាប់នេះក៏បានកំណត់ថា ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍដោយផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ។ ហើយច្បាប់នេះមានគោលដៅជំរុញ ឱ្យមានការគ្រប់គ្រងធនធានធម្មជាតិទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។

២. ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួពិនិត្យ ក្នុងការអនុវត្តន៍ច្បាប់នេះដោយមានការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធនានា និងក្របខ័ណ្ឌការងារពីស្ថាប័ន្ធពាក់ព័ន្ធផ្សេងៗ(មាត្រាទី៥ ៧ និងទី១០)។

៣. ជំពូកទី៦ នៃច្បាប់នេះក៏កំណត់ពីការធ្វើការពិគ្រោះយោបល់ពីសំណាក់ក្រសួងពាក់ព័ន្ធ ហើយមាត្រាទី២៣នៃជំពូកនេះបង្ហាញពីទឹកលើទីជម្រាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬ ធម្មជាតិ ចំណែកឯជំពូកទី៣វិញបានកំណត់ថាការយកខ្សាច់ ដី ថ្ម ក្រួស ប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរទន្លេ ស្ទឹង ព្រែក អូរបឹងបួរ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។

---

[1] Decision VII/28 of the Conference of the Parties to the Convention on Biological Diversity, annex.

[2] Decision X/2 of the Conference of the Parties to the Convention on Biological Diversity, annex. Accessible on line at: https://www.cbd.int/decision/cop/?id=12268

[3] World Bank, accessible at:
http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/EXTEAPREGTOPENVIRONMENT/0,,contentMDK:20266319~menuPK:3558191~pagePK:34004173~piPK:34003707~theSitePK:502886,00.html

[4] Dudley, N., K. J. Mulongoy, S. Cohen, S. Stolton, C. V. Barber and S. B. Gidda (2005). *Towards Effective Protected Area Systems. An Action Guide to Implement the Convention on Biological Diversity Programme of*

*Work on Protected Areas*. Secretariat of the Convention on Biological Diversity, Montreal, Technical Series No. 18, 108 pages.

[5] Decision VII/12, annex II, of the Conference of the Parties to the Convention on Biological Diversity. Accessible on line at: http://www.cbd.int/sustainable/addis.shtml

[6] http://www.cbd.int/ecosystem/

[7] http://www.cbd.int/sustainable/addis.shtml

[8] "In order to protect the environment, the precautionary approach shall be widely applied by States according to their capabilities. Where there are threats of serious or irreversible damage, lack of full scientific certainty shall not be used as a reason for postponing cost-effective measures to prevent environmental degradation." (Principle 15 of the 1992 Rio Declaration on Environment and Development)

[9] http://www.kellnielsen.dk/mekong/agreem.htm

[10] http://www.cbd.int/doc/pa/tools/Management%20Effectiveness%20Assessment%20of%20the%20System%20of%20Protected%20Areas%20in%20Cam.pdf

[11] http://www.mekong-protected-areas.org/cambodia/docs/cambodia_lessons.pdf

[12] United Nations General Assembly resolution 66/288 of 27 July 2012, annex.

[13] Cambodia biodiversity target 1: By 2020, knowledge of the stakeholders on biodiversity values has been improved. Indicators for target 1 include:

- Number of educational and media materials on biodiversity values have been developed.
- Number of stakeholders (schools, local communities, etc.) with wide knowledge of biodiversity values.

[14] http://www.mekong-protected-areas.org/cambodia/nr-summary.htm

[15] Hockings M., Stolton S., Dudley N. and James R., 2009, *Data credibility: what are the right data for evaluating management effectiveness of protected areas? Environmental Program and Policy Evaluation: Addressing Methodological Challenges* (*New Directions for Evaluation*), ed. M. Birnbaum and P. Mickwitz (Hoboken, NJ: Jossey-Bass) and Leverington F, Costa K L, Courrau J, Pavese H, Nolte C, Marr M, Coad L, Burgess N, Bomhard B and Hockings M 2010 Management Effectiveness Evaluation in Protected Areas—A Global Study 2nd edn (Brisbane: University of Queensland)

[16] The principles for good governance of protected areas developed by IUCN are accessible at:

http://data.iucn.org/dbtw-wpd/html/PAPS-016/3.%20Governance.html

[17] Decision X/31 paragraph 19 (a) of the Conference of the Parties to the Convention on Biological Diversity

[18] http://lifeweb.cbd.int/

[19] Decision X/31 paragraph 19 (a) of the Conference of the Parties to the Convention on Biological Diversity

[20] http://www.cbd.int/protected/implementation/actionplans/country/?country=kh

[21] http://www.cbd.int/protected/implementation/actionplans/country/?country=kh

[22] Guidelines for ecosystem valuation and related training modules have been published e.g. by The Economics of Ecosystems and Biodiversity – TEEB (http://www.teebweb.org/), the International Union for Conservation of Nature - IUCN (http://www.iucn.org/) and the Secretariat of the Convention on Biological Diversity – CBD (http://www.cbd.int/protected/)

រៀបចំដោយ

# នាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ
# អគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
# ក្រសួងបរិស្ថាន

ឧបត្ថម្ភដោយ

USAID
ជំនួយពីពលរដ្ឋអាមេរិក

យូសេដ តាមរយៈ:

គម្រោង កម្ពុជាហាវេស (Cambodia HARVEST)

និង

គម្រោង គាំទ្រព្រៃឈើ និងជីវៈចម្រុះ (SFB)